

# រួមដំណើរជាមួយ សន្តីតេរេសា ក្នុងព្រះរាជាណាចក្រកម្ពុជា

# មាតិកា


សារលិខិតលោកអភិបាល អូលីវីយេ ផ្ទិតហាស្លេរ .............................. ៣

ចំណាប់អារម្មណ៍គ្រីស្តបរិស័ទ .................................................. ៤

ប្រវត្តិសង្ខេបរបស់សន្តីតេរេសា ..................................................៧

ជីវិតប្រកបដោយរស្មីពន្លឺ ស្រីតូចតេរេសា នៅលីសឺយើស.....................៨

សន្តី តេរេសា និង ព្រះនាងព្រហ្មចារិនីម៉ារី.................................... ១៥

សន្តី តេរេសា និង គ្រួសារ.................................................... ២០

សន្តី តេរេសា និង ការត្រាស់ហៅ ............................................ ២៤

សន្តី តេរេសា និង សេចក្តីស្រឡាញ់...........................................៣២

សន្តី តេរេសា និង ព្រះយេស៊ូ..................................................៣៩

សន្តី តេរេសា និង ការអធិដ្ឋាន ............................................... ៤៣

សន្តី តេរេសា និង ព្រះកាយព្រះគ្រីស្ត ....................................... ៤៨

សន្តី តេរេសា និង មរណសាក្សីនៃសេចក្តីស្រឡាញ់ ........................ ៥៤

យើងទាំងអស់ សូមអរគុណសន្តី តេរេសា..................................... ៥៩



បងស្រី តេរេសា ជាទីស្រឡាញ់!

ពេលនេះ បងស្រីបានធ្វើដំណើរត្រឡប់ទៅប្រទេសបារាំងវិញហើយ ប៉ុន្តែកម្លាំងនៃសេចក្តីស្រឡាញ់របស់បងស្រី បានជោរជន់មកលើយើងខ្ញុំ ហើយបានណែនាំឲ្យព្រះសហគមន៍ដ៏តូចរបស់យើង ជួបជុំគ្នាយ៉ាងពិសេស...

នៅគ្រប់ទីកន្លែងដែលបងស្រីបានទៅដល់ មានមនុស្សម្នាជាច្រើនមកជួបជុំគ្នារង់ចាំស្វាគមន៍បងស្រី។

បងស្រីបានសាបព្រោះនូវគ្រាប់ពូជដ៏តូច នៅក្នុងដួងចិត្តយើងខ្ញុំ ជាគ្រាប់ពូជនៃអំណរសប្បាយ និងសន្តិភាព។

បងស្រីបានបើកភ្នែកយើងខ្ញុំ ឲ្យមើលឃើញការត្រាស់ហៅដែលនាំយើងខ្ញុំឲ្យធ្វើដំណើរឆ្ពោះទៅ ក្នុងភាពដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។

បងស្រីបានបំភ្លឺយើងខ្ញុំ និងកាន់ដៃយើងខ្ញុំឱ្យទទួលយកព្រះយេស៊ូទុកជាព្រះសង្គ្រោះរបស់ខ្លួន។

ដោយរួមជាមួយបងស្រី យើងខ្ញុំទាំងអស់គ្នាអង្គុយនៅទៀបបាទាព្រះមាតាសូមបន្លឺសូរស័ព្ទតែមួយថា៖ "ឱសឱ សន្តីតេរេសា! ដោយហេតុនេះហើយ បានជាយើងខ្ញុំស្រឡាញ់បងស្រីខ្លាំងណាស់"។

យើងខ្ញុំទាំងអស់គ្នា សូមអរគុណបងស្រីជាអនេក!

អាលេលូយ៉ា! សូមបងប្អូនជាទីស្រឡាញ់! យកចិត្តទុកដាក់អានសៀវភៅនេះ ដោយនឹករឭកដល់សន្តីតេរេសា ដែលបានមកសួរសុខទុក្ខយើង។

**អូលីវីយេ ស្មិតហាស្លេរ**

អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ

# ចំណាប់អារម្មណ៍គ្រីស្តបរិស័ទ
## ចំពោះដំណើរសួរសុខទុក្ខរបស់សន្តី តេរេសា

ថ្ងៃនេះជាទិវាដ៏ពិសិដ្ឋ និង ប្រកបដោយសិរីរុងរឿងយ៉ាងក្រៃលែង ដែលយើងបានរួមគ្នាទទួលស្វាគមន៍នូវអដ្ឋិធាតុ សន្តីតេរេសានៃព្រះកុមារយេស៊ូ ជាទីសក្ការៈ ជាសន្តីបុគ្គលប្រកបដោយសីលធម៌ដ៏ប្រសើរឧត្តម មានសេចក្តីស្រឡាញ់យ៉ាងខ្លាំង និងជំនឿយ៉ាងមុតមាំ សុខចិត្តធ្វើជីវិតទាំងស្រុងលើព្រះយេស៊ូអស់មួយជីវិត ។

តាមរយៈជីវប្រវត្តិ បានបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ថា បងស្រីតេរេសាមានជំនឿលើព្រះជាម្ចាស់ខ្លាំងណាស់ តាំងពីកុមារភាពមកម្ល៉េះ បងស្រីបានយកព្រះយេស៊ូជាគំរូ បានយកព្រះនាងម៉ារីជាគំរូ ដើម្បីកែប្រែផ្លាស់ប្តូរអត្តចរិតមិនល្អ និងភាពចចេសរឹងរូសរបស់គាត់ ហើយបន្តិចម្តងៗ គាត់ក៏បានក្លាយទៅជាបុគ្គលប្រកបដោយចរិយាថ្លៃថ្នូរ សីលធម៌ ខ្ពង់ខ្ពស់។ ម្យ៉ាងទៀតដោយសារសេចក្តីស្រឡាញ់និងជំនឿ ញ៉ាំងឲ្យសន្តីតេរេសាមានចិត្តក្លាហាន ហ៊ានសុំការអនុញ្ញាតពីសម្តេចប៉ាបនៅទីក្រុងរ៉ូម ដើម្បីបួសក្នុងអារាមកាមែល ដោយលះបង់ចោលទាំងស្រុងជីវិតលោកីយ៍។ ទន្ទឹមនឹងនេះដែរ ជារៀងរាល់ថ្ងៃ សន្តីតេរេសាចូលចិត្តយកអាសារអ្នកដទៃ យកឈ្នះអស់សេចក្តីល្បួង ដោយបង្ហាញសេចក្តីស្រឡាញ់ មេត្តាករុណាដ៏បរិសុទ្ធដែលមកពីព្រះជាម្ចាស់ដល់អ្នកឯទៀតៗ រហូតដល់ថ្ងៃដែលគាត់ទទួលមរណភាព។ តាមការពិត បងស្រីតេរេសារស់នៅយ៉ាងសាមញ្ញធម្មតាដូចយើងដែរ គ្រាន់តែបងស្រីបានជ្រើសរើសរបៀបរស់នៅជាអ្នកបួស ក្នុងអារាមបងស្រីសម្ងាត់ ដោយថ្វាយខ្លួនទាំងស្រុងទៅព្រះយេស៊ូ ទាំង

បានបង្ហាញមាគ៌ាដ៏តូចមួយ គឺសេចក្តីស្រឡាញ់ដើម្បីឆ្ពោះទៅកាន់ព្រះបិតា ហើយបងស្រីក៏បានក្លាយទៅជាសន្តីបុគ្គលដ៏ជាទីគោរព កោតសរសើរបំផុតក្នុងសកលលោកនៅសតវត្សទី២១ នេះ។

ជាក់ស្តែងថ្ងៃនេះ អដ្ឋិធាតុរបស់សន្តីតេរេសាដ៏ជាទីសក្ការៈកំពុងមានវត្តមាននៅក្នុងព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាយើង ជាពិសេស ពេលនេះគឺនៅចំពោះមុខយើង នៅព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹមចម្ការទៀង។ ពេលវេលាដ៏សក្ការៈនេះ គឺព្រះជាម្ចាស់កំពុងតែបង្ហាញនូវសិរីរុងរឿង ហើយព្រះអង្គក៏កំពុងសម្តែងនូវឫទ្ធានុភាព គឺសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះយើងម្នាក់ៗ ដែលបណ្តាលឲ្យយើងញាប់ញ័រក្នុងចិត្តដោយសេចក្តីរំភើបផង និងដោយអំណរសប្បាយផង និងទាក់ទាញយើងម្នាក់ៗឲ្យមានចិត្តក្លាហាន បើកចិត្តទទួលព្រះយេស៊ូទុកក្នុងជីវិតរបស់ខ្លួន ដោយយកសន្តីតេរេសាទុកជាវីរគំរូដ៏អស្ចារ្យ ក្នុងការរស់នៅរបស់ពួកយើងម្នាក់ៗ។ ពេលនេះ ទោះបីសន្តីតេរេសាបានទទួលមរណភាពតាំងពី១១៦ឆ្នាំមុនទៅហើយក្តី ក៏ប៉ុន្តែអដ្ឋិធាតុរបស់បងស្រីនិងប្រវត្តិនៃព្រលឹងតូចមួយ ដែលបានធ្វើបូជនីយចរទូទាំងពិភពលោកនោះបានក្លាយទៅជាសក្ខីភាពនៃជំនឿដល់គ្រីស្តបរិស័ទជាច្រើនក្នុងសកលលោកទាំងមូល ជាពិសេសពេលនេះដល់យើងជាគ្រីស្តបរិស័ទខ្មែរដែរ។

ឆ្លៀតក្នុងឱកាសដ៏មានអត្ថន័យនេះ យើងខ្ញុំសូមបួងសួងដល់សន្តីតេរេសាដែលរស់នៅរួមនៅជាមួយព្រះបិតាឯស្ថានបរមសុខ មេត្តាបង្ហាញផ្លូវ ផ្តល់កម្លាំងចិត្តដល់យើងខ្ញុំជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ឲ្យមានជំនឿកាន់តែរឹងមាំ សុខចិត្តរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ និងឲ្យយើងខ្ញុំសុខចិត្តផ្ញើជីវិតទាំងស្រុងលើព្រះគ្រីស្តអស់មួយជីវិតផង។

យើងខ្ញុំទាំងអស់គ្នា ក៏សូមថ្លែងអំណរគុណដល់លោកអភិបាលយ៉ាងជ្រាលជ្រៅបំផុត ដែលលោកបានបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃព្រះសហគមន៍កាតូលិក

នៅប្រទេសកម្ពុជាយើង គឺលោកបានផ្ដល់ឱកាសដ៏កម្រជាច្រើនដល់គ្រីស្ដបរិស័ទនៅប្រទេសកម្ពុជាយើង ជាពិសេសពេលនោះឲ្យគ្រីស្ដបរិស័ទយើងបានគោរពអដ្ឋិធាតុសន្ដីតេរេសា ដែលជាសក្ខីភាពខាងផ្លូវវិញ្ញាណដោយផ្ទាល់ ឲ្យមានជំនឿកាន់តែរឹងមាំឡើង ឲ្យមានពន្លឺដើរឆ្ពោះទៅកាន់ព្រះបិតាដែលស្រឡាញ់យើង។

សូមសន្ដីតេរេសា និងសន្ដបុគ្គលទាំងឡាយ អង្វរព្រះជាម្ចាស់ សូមព្រះអង្គជួយគាំពារលោកអភិបាល ឲ្យជួបតែសេចក្ដីសុខសាន្ដគ្រប់ពេលវេលា។

តំណាងគ្រីស្ដបរិស័ទនៅព្រះសហគមន៍ចម្ការទៀង

**គុល ជៀង**

# ប្រវត្តិសង្ខេបរបស់សន្តី តេរេសា

សន្តី តេរេសា ជាជនជាតិបារាំង។ កើតនៅថ្ងៃទី០២ ខែមករា ឆ្នាំ១៨៧៣ និងទទួលមរណភាពនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៨៩៧ ដោយសារជំងឺរបេង ក្នុងអាយុ ២៤ ឆ្នាំ។

គាត់ចង់បួសតាំងពីអាយុ ១៣ ឆ្នាំ ប៉ុន្តែគាត់ជួបឧបសគ្គជាច្រើន ហើយទីបញ្ចប់គាត់បានចូលបួសក្នុងក្រុមដូនជីសម្ងាត់នៅឆ្នាំ១៨៨៨ ក្នុងអាយុ ១៥ ឆ្នាំ នៅភូមិលីស៊ីយើ ក្នុងខេត្តណ័រម៉ង់ឌី។

បន្ទាប់ពីបួសជាដូនជីក្នុងក្រុមដូនជីសម្ងាត់អស់រយៈ៩ឆ្នាំគាត់បានបំពេញមុខងារជាអ្នកអប់រំអ្នកបួសថ្មី។ គាត់ជាមនុស្សល្បីល្បាញ ព្រោះគាត់រស់នៅប្រកបដោយសីលធម៌ខ្ពស់ និងគាត់ជាមនុស្សដែលមានប្រាជ្ញាមកពីព្រះវិញ្ញាណ។

គាត់សរសេរសៀវភៅមួយឈ្មោះថា "រឿងរ៉ាវនៃព្រលឹងមួយ" ដែលបានបោះពុម្ពផ្សាយ ១ ឆ្នាំ ក្រោយពេលគាត់ទទួលមរណភាព។ សៀវភៅនោះ ល្បីល្បាញណាស់ ត្រូវបានគេបោះពុម្ពជាច្រើនភាសា និងបោះពុម្ពសាជាថ្មីជាច្រើនដងទៀតផង។

សន្តីតេរេសា ក្លាយទៅជាសន្តីម្នាក់ ដែលគេចូលចិត្តក្នុងចំណោមសន្តីទាំងឡាយ នៅសតវត្សទី២០ នេះ។ សន្តីតេរេសា ស្រឡាញ់ប្រជាជននៅទ្វីបអាស៊ីណាស់ គាត់ស្ម័គ្រចិត្តមករស់នៅទ្វីបអាស៊ី ក្នុងអារាមមួយ។ គាត់ធ្លាប់សរសេរសំបុត្រទៅសួរសុខទុក្ខក្រុមអ្នកបួស ដែលរស់នៅក្នុងប្រទេសចិន។

តាមពិតទៅ អដ្ឋិធាតុរបស់សន្តីបុគ្គលដ៏ល្បីល្បាញដូចគាត់ បានមកដល់ប្រទេសកម្ពុជាយ៉ាងដូច្នេះ នោះជាព្រឹត្តិការណ៍ដ៏មានអត្ថន័យមួយ សម្រាប់ប្រជាជនកម្ពុជាយើង ដែលមានបំណងចង់គោរពអ្នកដែលផ្តល់គំរូរស់នៅប្រកបដោយសីលធម៌ខ្ពស់ដ៏ល្បីល្បាញដូចគាត់។

# ជីវិតប្រកបដោយរស្មីពន្លឺ
## ស្រីតូចតេរេសា នៅលីស៊ីយើ

នេះគឺ ម៉ារី ប៉ូលីន ឡេអូនី និងសេលីន ដែលជាកូនស្រីរបស់លោក ម៉ាតាំង និងអ្នកស្រីហ្សេលី។ ពួកនាងកំពុងតែសប្បាយរីករាយជុំវិញអង្រឹងរបស់ប្អូនស្រីតូចដែលទើបនឹងកើតក្នុងថ្ងៃទី២ ខែមករា ឆ្នាំ១៨៧៣ នេះ នៅអាឡង់សុង ហើយគេដាក់ឈ្មោះឲ្យទារិកានេះថា តេរេសា។ តេរេសាជាកូនង៉ែតតូចមួយដូចកូនង៉ែតឯទៀតៗដូច្នោះដែរ ប៉ុន្តែថ្ងៃមួយនោះ សកលលោកទាំងមូលបានស្គាល់ និងស្រឡាញ់កូនង៉ែតនោះយ៉ាងខ្លាំង កូនង៉ែតនោះគឺជាសន្ទីតេរេសានៃព្រះកុមារយេស៊ូ និងព្រះភក្ត្រដ៏វិសុទ្ធនេះតែម្តង។

តេរេសាចម្រើនវ័យក្នុងក្រុមគ្រួសារដែលស្រឡាញ់ និងថ្នាក់ថ្នមនាងណាស់។ ឪពុករបស់នាងហៅនាងថា "ម្ចាស់ក្សត្រីតូចរបស់ពុក"។

ក្មេងស្រីតូចនេះ មិនសូវជាស្លូតបូតប៉ុន្មានទេ ប៉ុន្តែនាងខិតខំកែប្រែអាកប្បកិរិយារបស់នាងបន្តិចម្តងៗ ដើម្បីឲ្យគាប់ព្រះហឫទ័យព្រះយេស៊ូ។

នាងចូលចិត្តអធិដ្ឋាន៖ នាងទូលព្រះយេស៊ូថា នាងស្រឡាញ់ព្រះអង្គណាស់ និងអរព្រះគុណព្រះអង្គ ដែលបានប្រទានភាពរីករាយដល់នាង ហើយនាងក៏យកទុក្ខព្រួយទាំងប៉ុន្មានមកទូលថ្វាយព្រះអង្គដែរ។

ពេលនាងមានអាយុ ៤ឆ្នាំ ទុក្ខសោកមួយយ៉ាងធំបានមកគ្របដណ្តប់លើក្រុមគ្រួសារ៖ អ្នកម្តាយមានជំងឺជាទម្ងន់ ហើយបាត់បង់ជីវិតទៅ។ ឥឡូវនេះមានតែបងស្រីប៉ូលីនប៉ុណ្ណោះ ដែលជាអ្នកលួងលោមថ្នាក់ថ្នមនាងជំនួសម្តាយ ហើយនាងហៅគាត់ថា "ម៉ាក់តូចៗ!"។

នៅខែវិច្ឆិកា ឆ្នាំ១៨៧៧ លោកម៉ារតាំង និងកូនស្រីទាំងអស់ចាកចេញពីអាឡង់សុងទៅរស់នៅឯលីស៊ីយើ ក្នុងគេហដ្ឋានធំទូលាយមួយ ដែលគេដាក់ឈ្មោះថា "ព្រៃគុម្ពោតតូច"។ នៅទីនោះ តេរេសាឧស្សាហ៍ទៅលេងនឹងលោកមាអ្នកមីង និងបងស្រីជីដូនមួយពីរនាក់របស់នាង។

ជួនកាលឪពុកនាងនាំនាងទៅស្ទូចត្រី។ ក្មេងស្រីតូចនេះចូលចិត្តគយគន់ធម្មជាតិ ហើយនឹកគិតថា ព្រះជាម្ចាស់ប្រទានអ្វីៗគ្រប់បែបយ៉ាងមកយើងពីព្រោះព្រះអង្គស្រឡាញ់ពួកយើង។

ថ្ងៃមួយ ប៉ូលីនសម្រេចចិត្តថា ទៅបួសជាដូនជីនៅអារាមការមែលនៅលីស៊ីយើ។ ស្រីតូចតេរេសាកើតទុក្ខក្រៀមក្រំយ៉ាងខ្លាំង ក្រោយពីបានដឹងរឿងនេះហើយនាងធ្លាក់ខ្លួនឈឺជាទម្ងន់។ ប៉ុន្តែ នាងមានអារម្មណ៍ថា បានជាសះស្បើយវិញភ្លាម នៅពេលនាងបានមើលឃើញរូបចម្លាក់របស់ព្រះនាងម៉ារីដ៏វិសុទ្ធដែលតាំងនៅក្បែរគ្រែ ញញឹមដាក់នាង។

ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៨៨៤ ជាថ្ងៃប្រកបដោយសុភមង្គល ដែលតេរេសាបានទទួលព្រះកាយព្រះគ្រីស្តជាលើកដំបូង។ នាងហៅថ្ងៃនោះថា ជា "ថ្ងៃដំបូងដែលព្រះកាយថើបព្រលឹងខ្ញុំ"។

បន្ទាប់ពី ប៉ូលីន និង ម៉ារី ចូលទៅនៅអារាមការមែល ឥឡូវនេះ តេរេសាក៏ចង់ក្លាយទៅជាដូនជីដែរ។ ឪពុកនាងយល់ព្រមចំពោះបំណងនេះ ប៉ុន្តែ គាត់កើតទុក្ខព្រួយខ្លាំង។

ទោះបីឪពុកនាងយល់ព្រមក៏ដោយ ក៏តេរេសាមិនអាចទៅបួសបានដែរ ព្រោះនាងនៅក្មេងពេក៖ នាងទើបតែអាយុដប់ប្រាំឆ្នាំប៉ុណ្ណោះ លោកអភិបាលព្រះសហគមន៍មិនយល់ព្រមឲ្យចូលបួសទេ។ ពេលនោះ លោកម៉ារតាំងបាននាំសេលីន និងតេរេសា ទៅធ្វើបូជនីយេសចរណ៍នៅទីក្រុងរ៉ូម។

នៅវ៉ាទីកង់ តេរេសាហ៊ានចូលទៅសូមការអនុញ្ញាតពីសម្ដេចប៉ាប ដើម្បីមានសិទ្ធិចូលបួសក្នុងអារាមការមែលទាំងនាងមានអាយុដប់ប្រាំឆ្នាំ។ សម្ដេចប៉ាបគ្រាន់តែឆ្លើយតបទៅនាងថា៖ "បើជាព្រះបំណងរបស់ព្រះជាម្ចាស់ នោះនាងមុខជានឹងបានចូលបួសមិនខាន"។

ពេលមកដល់លីស៊ីយើវិញ តេរេសាបានទទួលសំបុត្រមួយពីលោកអភិបាលព្រះសហគមន៍យល់ព្រមឲ្យនាងចូលបួស។ នាងត្រូវបានអនុញ្ញាតឲ្យទៅរស់នៅក្នុងអារាមការមែល ទោះជានាងមានអាយុតិចក៏ដោយ។

នាងបានទទួលការអនុញ្ញាតឲ្យចូលបួសក្នុងករណីយ៉ាងពិសេស។ ហេតុដូច្នេះហើយទើបបងស្រីខ្លះបានប្រព្រឹត្តយ៉ាងតឹងរឹងចំពោះនាង ដើម្បីកុំឲ្យនាងមានអំនួត។ មានបងស្រីខ្លះស្ដីបន្ទោសនាងយ៉ាងខ្លាំង។ ដោយសារសេចក្ដីស្រឡាញ់ចំពោះព្រះយេស៊ូ តេរេសាបានទ្រាំទ្រទទួលការលំបាកសព្វបែបយ៉ាងជាមួយនឹងស្នាមញញឹម។

ថ្ងៃទី១០ ខែមករា ឆ្នាំ១៨៨៩ ទោះជាមានសុខភាពមិនល្អក៏ដោយ ក៏លោកម៉ាតាំងជាឪពុករបស់តេរេសា បានអញ្ជើញមកចូលរួមក្នុងពិធីដ៏រំភើបចិត្តមួយ គឺការទទួលសម្លៀកបំពាក់ជាអ្នកបួសរបស់ "ម្ចាស់ក្សត្រីតូចរបស់គាត់"។ ចាប់ពីថ្ងៃនោះតទៅ តេរេសានឹងស្លៀកពាក់តាមរបៀបជាដូនជីនៅអារាមការមែលនោះរហូត។

ថ្ងៃទី៩ ខែមេសា ឆ្នាំ១៨៨៨ តេរេសាបានសម្រេចបំណងរបស់នាងហើយ។ ទីបំផុត ទ្វារអារាមការមែលបានបើកទូលាយទទួលនាង ហើយនាងនឹងធ្វើពិធីថ្វាយខ្លួនទាំងស្រុងចំពោះព្រះយេស៊ូ នៅពេលខាងមុខនេះ។

ឥឡូវនេះ នាងស្លៀកពាក់ពណ៌សតាមរបៀបជាយុវនារីដែលចាប់ផ្ដើមជីវិតជាអ្នកបួស ហើយក្នុងមួយថ្ងៃៗនាងត្រូវរកពេលវេលាដើម្បីអធិដ្ឋាន ដើម្បីរៀនសូត្រ និងបំពេញការងារតូចតាចផ្សេងៗប្រចាំថ្ងៃដូចបងស្រីឯទៀតៗដែរ។

បរិយាកាសខាងក្រៅ ត្រូវព្រិលគ្របដណ្ដប់ពាសពេញពីលើ។ តេរេសាសប្បាយចិត្តណាស់ ដ្បិតធម្មជាតិទាំងអស់ត្រូវគ្របដណ្ដប់ដោយស្បៃពណ៌សដូចរូបនាងដែលបានស្លៀកពាក់ពណ៌សដែរ។ ចាប់ពីពេលនេះទៅ នាងឈ្មោះថា "ប្អូនស្រីតេរេសានៃព្រះកុមារយេស៊ូ"។

នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៨៩០ ជាពេលដែលតេរេសាថ្វាយពាក្យសច្ចាមួយជីវិតនេះ គឺថ្វាយខ្លួនទាំងស្រុងចំពោះព្រះយេស៊ូជាអម្ចាស់។ ស្បៃគ្របមុខពណ៌សរបស់នាងត្រូវជំនួសដោយស្បៃខ្មៅទៅវិញ។

បងស្រីដឹងច្បាស់ថា ដើម្បីស្រឡាញ់ព្រះយេស៊ូឲ្យបានពិតប្រាកដ នោះត្រូវស្រឡាញ់អ្នកដែលរស់នៅជាមួយ។ ហេតុនេះហើយ ទើបបងស្រីខិតខំធ្វើឲ្យបងស្រីឯទៀតៗស្រឡាញ់គាត់ និងជួយយកអាសាបងស្រីឯទៀតៗ ជាពិសេសបងស្រីដែលមិនចូលចិត្តគាត់។

បងស្រីតេរេសាមានអំណោយទានខាងសិល្បៈ ខាងគូររូបបុគ្គលដែលគេគោរព ឬតុបតែងលម្អវត្ថុនានាសម្រាប់សាសនា។ បងស្រីសរសេរកំណាព្យ និងរឿងល្ខោន ហើយដើរតួដោយខ្លួនឯងជាមួយនឹងបងស្រីឯទៀតដែរ។

ថ្ងៃខែឆ្នាំចេះតែកន្លងទៅ។ បងស្រីតេរេសាបានទទួលមុខងារថ្មី គឺបង្រៀនប្អូនស្រីឯទៀតៗ ដែលជាអ្នកត្រៀមខ្លួនចូលបួស ឲ្យចេះប្រកាន់ឥរិយាបទចំពោះព្រះជាម្ចាស់ក្នុងឋានៈបុត្រធីតារបស់ព្រះអង្គ ឲ្យមានចិត្តស្រឡាញ់ព្រះបិតាដោយចិត្តស្មោះត្រង់ផង។

បងស្រីតេរេសាធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរណាស់។ បងស្រីចេះតែអស់កម្លាំងខ្សោយទៅៗ ហើយក្អកជាញឹកញាប់ផង។ ពេលនោះ អ្នកទទួលខុសត្រូវ គឺដូនជីអាញ៉េស (បងស្រី ប៉ូលីនជាបងបង្កើតរបស់គាត់) បានណែនាំឲ្យបងស្រីតេរេសា សរសេររៀបរាប់អំពីខ្សែជីវិតផ្ទាល់ខ្លួនរបស់គាត់ជាលាយលក្ខណ៍អក្សរ។ រឿងនិទាននេះក៏បានក្លាយទៅជាសៀវភៅមួយដែលមានចំណងជើងថា "ប្រវត្តិនៃព្រលឹងមួយ"។

ពេលនោះ បងស្រីតេរេសាចុះខ្សោយដើរស្ទើរតែពុំរួច។ ប៉ុន្តែ បងស្រីខិតខំដើរឲ្យបានពីរ ឬ បី ជំហាន ដោយកំណត់ក្នុងចិត្តថា "ខ្ញុំដើរដើម្បីសាសនទូតម្នាក់"។ តាមពិតទៅ បងស្រីតេរេសាធ្លាប់សរសេរសំបុត្រគាំទ្រលើកទឹកចិត្តជាច្រើនផ្ញើជូនទៅសាសនទូតពីររូប ហើយបងស្រីក៏បានអធិដ្ឋានសូមឲ្យព្រះយេស៊ូជួយគាំទ្រដល់សាសនទូតទាំងពីររូបនោះផងដែរ។

នៅខែកក្កដា ឆ្នាំ១៨៩៧ គេនាំបងស្រីតេរេសាទៅសម្រាកព្យាបាលនៅក្នុងគិលានដ្ឋានប្រចាំអារាម។ បងស្រីដឹងថា ជីវិតដល់ថ្ងៃបញ្ចប់ហើយ ហើយគាត់និយាយថា "ខ្ញុំមិនស្លាប់ទេ តែខ្ញុំដើរចូលទៅក្នុងជីវិតវិញ"។

ថ្ងៃទី៣០ ខែកញ្ញា សភាពជំងឺរបស់បងស្រីតេរេសាកាន់តែដុនដាបទៅៗ។ ដោយសម្លឹងមើលទៅព្រះឈើឆ្កាង បងស្រីស្រែកឡើងថា៖ "ឱ! ព្រះជាម្ចាស់អើយ ខ្ញុំស្រឡាញ់ព្រះអង្គខ្លាំងណាស់! ឱ! ព្រះជាម្ចាស់អើយ ខ្ញុំស្រឡាញ់ព្រះអង្គខ្លាំងណាស់!"។ នោះគឺជាសម្តីចុងក្រោយបំផុតរបស់សន្តីតេរេសា...។





















# សន្តី តេរេសា
# និង ព្រះនាងព្រហ្មចារិនីម៉ារី (អរិយក្សត្រ)

ថ្ងៃនេះ ជាលើកទីមួយហើយដែលសន្តីតេរេសា បានមកដល់ទឹកដីនៃប្រទេសកម្ពុជា ណែនាំឲ្យយើងមានអំណរសប្បាយយ៉ាងខ្លាំង។ ពេលនេះ សន្តីតេរេសា បានមកដល់ព្រះសហគមន៍អរិយក្សត្រ ជាកន្លែងដែលយើងគោរពព្រះនាងម៉ារីយ៉ាងពិសេស។ ខ្ញុំសូមបង្ហាញខ្លះៗ អំពីទំនាក់ទំនងរវាងសន្តីតេរេសា និងព្រះនាងម៉ារី ជូនបងប្អូនទាំងអស់គ្នារិះគិត។ សម្រាប់សន្តីតេរេសា ព្រះនាងម៉ារីសំខាន់ណាស់ ទំនាក់ទំនងរវាងសន្តីតេរេសា និងព្រះនាងម៉ារី ជាទំនាក់ទំនងយ៉ាងពិសេស ដោយសារសន្តីតេរេសាបានបង្កើតទំនាក់ទំនងបន្តិចម្តងៗជាមួយព្រះនាងម៉ារីពេញមួយជីវិតរបស់គាត់។

ពេលសន្តីតេរេសា មានអាយុ៤ឆ្នាំកន្លះ ម្តាយរបស់គាត់បានទទួលមរណភាពដោយសារជំងឺរបេង ពេលនោះ សន្តីតេរេសា ពិបាកចិត្តមែនទែន ជាហេតុធ្វើឲ្យគាត់ចាប់ផ្តើមឈឺក្បាលរហូត។ ទោះបីសន្តីតេរេសា ជិតស្និទ្ធជាមួយព្រះយេស៊ូយ៉ាងណាក៏ដោយ ក៏គាត់ទៅជាមនុស្សម្នាក់យ៉ាងពិបាកដែរ ពីព្រោះគាត់ខ្វះសេចក្តីស្រឡាញ់ និងភាពកក់ក្តៅពីម្តាយតាំងពីនៅវ័យក្មេងពេក។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៨៨៣ សន្តីតេរេសាឈឺសម្រាកនៅលើគ្រែ ពេលនោះ គាត់សម្លឹងមើលទៅរូបព្រះនាងម៉ារី ហើយស្រាប់តែគាត់ឃើញព្រះនាងញញឹមដាក់គាត់ ដែលបណ្តាលឲ្យគាត់មានកម្លាំងជាថ្មី គាត់ហាក់បីដូចជាបានជាសះស្បើយពីជំងឺទាំងអស់ គាត់ដូចជាបានទទួលជីវិតថ្មីវិញ ណែនាំឲ្យគាត់អាចទៅមុខទៀតបាន។ ថ្ងៃនោះដែរ សន្តីតេរេសា បានទូលសូមយកព្រះនាងម៉ារីធ្វើជាម្តាយរបស់គាត់។

ក្រោយមក សន្តីតេរេសាបានចូលបួសក្នុងអារាមកាមែល ជាកន្លែងដែលបងស្រីរស់នៅយ៉ាងស្ងាត់ ដើម្បីអធិដ្ឋានសម្រាប់ព្រះសហគមន៍ និងសម្រាប់ពិភពលោកទាំងមូល។ តាមពិតអារាមកាមែល ក៏យកព្រះនាងម៉ារីជាឧបការីដែរ ដូច្នេះសន្តីតេរេសា ដែលបានយកព្រះនាងម៉ារីទុកជាម្តាយ ឥឡូវនេះបានចូលបួសក្នុងក្រុមគ្រួសារដូនជី ដែលបានយកព្រះនាងម៉ារីទុកជាឧបការីដែរ។ សន្តីតេរេសា បានផ្ញើជីវិតទាំងស្រុង ទៅលើធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដោយគាត់បានផ្ញើជីវិតទាំងស្រុង ក្នុងហត្ថារបស់ព្រះនាងម៉ារី ដើម្បីព្រះនាងមើលថែរក្សា គាំទ្រ និងស្រឡាញ់គាត់ថែមទៀតដែរ។

ឆ្នាំ១៨៩៧ សន្តីតេរេសា បានសរសេរកំណាព្យមួយ ប្រហែល៤ខែមុនគាត់ទទួលមរណភាពដោយសារជំងឺរបេង។ ក្នុងកំណាព្យនោះ បានរៀបរាប់អំពីព្រះនាងម៉ារីដែលគាត់ស្រឡាញ់ និងដែលគាត់ភ្ជាប់ចិត្តជាមួយអស់មួយជីវិតរបស់គាត់។ សន្តីតេរេសា បានអានព្រះគម្ពីរដំណឹងល្អ ដែលទាក់ទងនឹងព្រះនាងម៉ារី គឺចាប់តាំងពីទេវទូតកាព្រីអែលជូនដំណឹងដល់ព្រះនាង ពេលព្រះនាងសុខចិត្តទទួលប្រសូតបុត្រមួយថ្វាយព្រះជាម្ចាស់ គឺជាព្រះយេស៊ូរហូតដល់ព្រះនាងម៉ារី ចូលរួមក្នុងពិធីមង្គលការនៅភូមិកាណា ពេលព្រះនាងម៉ារីធ្វើដំណើរតាមរកព្រះកុមារយេស៊ូ នៅក្រុងយេរូសាឡឹម និងចាំទុកពាក្យសម្តីរបស់ព្រះកុមារទាំងអស់នៅក្នុងដួងចិត្ត រហូតដល់ព្រះនាងម៉ារីនៅក្បែរឈើឆ្កាងនៅពេលព្រះយេស៊ូរងទុក្ខលំបាក និងសោយទិវង្គត។ នេះជាជីវិតរបស់ព្រះនាងម៉ារីដែលជាប់នឹងព្រះយេស៊ូ ដែលណែនាំឲ្យសន្តីតេរេសាចាប់អារម្មណ៍យ៉ាងខ្លាំង និងគាត់បានសរសេរថា៖

> ទីមួយ ព្រះនាងម៉ារី មិនមែនជាព្រះមហាក្សត្រី មិនមែនជាមនុស្សម្នាក់ដែលអស្ចារ្យទេ តែព្រះនាងជាគ្រីស្តបរិស័ទដំបូងគេបង្អស់ គឺតាំងពីព្រះនាងបានយល់ព្រមធ្វើជាមាតារបស់ព្រះឱរសយេស៊ូ។ ព្រះនាងជាយុវនារី ជាមាតា ជាស្ត្រីសាមញ្ញធម្មតាម្នាក់ ដែលយើងអាចធ្វើដូចព្រះនាងបាន ព្រះនាងមិននៅឆ្ងាយពីយើងទេ តែព្រះនាងធ្វើដំណើរ

ជាមួយយើងជាគ្រីស្តបរិស័ទ។ ព្រះនាងម៉ារីជាព្រះមហាក្សត្រី ជាព្រះមាតា ជាម្តាយ ដោយហេតុនេះហើយ ទើបសន្តិតេរេសា បានយកព្រះនាងទុកជាម្តាយរបស់គាត់។

ទីពីរ ព្រះនាងម៉ារីបានរស់នៅក្នុងជំនឿដូចយើង មានអំណរសប្បាយនៅពេលទទួលដំណឹងថា នឹងធ្វើជាមាតារបស់ព្រះយេស៊ូ នៅពេលទៅចែកអំណរសប្បាយជាមួយយាយអេលីសាប៉ែត នៅពេលព្រះយេស៊ូប្រសូត...។ ព្រះនាងម៉ារីក៏មានទុក្ខលំបាកដូចយើងដែរ គឺនៅពេលឮព្រះយេស៊ូមានព្រះបន្ទូលថា "អ្នកណាជាម្តាយរបស់ខ្ញុំ?" នៅពេលព្រះយេស៊ូសោយទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង ជាពេលវេលាដែលព្រះនាងឈឺចាប់យ៉ាងខ្លាំង ដោយសារកូនជាទីស្រឡាញ់រងទុក្ខវេទនានិងស្លាប់នៅចំពោះមុខខ្លួន។ ដូច្នេះ ព្រះនាងម៉ារីបានរស់នៅក្នុងជំនឿដូចយើង ដែលមានទាំងអំណរ មានទាំងទុក្ខព្រួយ ដោយលីឈើឆ្កាង ដោយទុកអ្វីទាំងៗអស់នៅក្នុងដួងចិត្ត ដើម្បីធ្វើដំណើរនៅក្នុងជំនឿ។ សព្វថ្ងៃ ដោយសារជំនឿ យើងក៏ធ្វើអ្វីៗទាំងអស់ទៅព្រះជាម្ចាស់ដែរ ជីវិតរបស់យើងឥតមានគម្រោងការអ្វីមួយផ្សេងក្រៅពីនេះទេ។

សន្តិតេរេសាបានសរសេរបន្តថា៖ "ព្រះនាងម៉ារីជាតំណាងព្រះសហគមន៍ដែលបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ចំពោះមនុស្សលោក"។ នៅភូមិកាណា ក្នុងពិធីមង្គលការ ព្រះនាងម៉ារីបានប្រាប់ទៅអ្នកបម្រើថា៖ "ចូរធ្វើតាមលោកប្រាប់ទៅ!" សេចក្តីនេះមានន័យថា ព្រះនាងម៉ារីធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់គ្រប់ពេលវេលាជានិច្ច ដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់។ សេចក្តីនេះន័យចំពោះព្រះសហគមន៍ ហើយយើងអាចនិយាយបានថា ព្រះនាងម៉ារីជាតំណាងរបស់ព្រះសហគមន៍ ដែលបង្ហាញធម៌មេត្តាករុណាដល់មនុស្សទាំងអស់។

ព្រះនាងម៉ារី ជាមនុស្សតូចតាចម្នាក់ដែលព្រះជាម្ចាស់បានជ្រើសរើស។ ព្រះនាងបានច្រៀងកោតសរសើរព្រះជាម្ចាស់អស់ពីដួងចិត្ត នៅពេលព្រះនាង

បានទទួលដំណឹងថា នឹងទៅជាមាតារបស់ព្រះជាម្ចាស់ នៅពេលទៅសួរសុខទុក្ខយាយអេលីសាប៉ែត។ ការណ៍ទាំងនេះបង្ហាញថា ព្រះនាងជាមនុស្សតូចតាច ជាមនុស្សសុភាពរាបសា ជាមនុស្សគ្មានអំណាច ប៉ុន្តែព្រះជាម្ចាស់បានជ្រើសរើសព្រះនាង។ ឯផ្លូវដែលសន្តីតេរេសាបានបង្កើត ក៏ជាផ្លូវតូចតាចដែរ គាត់អញ្ជើញយើងម្នាក់ៗ ឲ្យដើរលើផ្លូវតូចតាចមួយ ដោយដឹងថា មានព្រះយេស៊ូជាទីពឹង មានព្រះយេស៊ូធ្វើដំណើរជាមួយ ហើយបើយើងសុខចិត្តទទួលស្គាល់ថាខ្លួនជាមនុស្សតូចតាច ជាមនុស្សទន់ខ្សោយ ជាមនុស្សមានបាបពិតមែន នោះព្រះយេស៊ូជំរុញឲ្យយើងអាចធ្វើដំណើរទៅមុខបាន ដូចព្រះអង្គមានព្រះបន្ទូលថា៖ "អ្នកណាដាក់ខ្លួនជាអ្នកក្រខ្សត់ អ្នកនោះពិតជាមានសុភមង្គលហើយ"។

ដូច្នេះ យើងត្រូវតែពឹងលើព្រះយេស៊ូទាំងស្រុង ដូចកូនទីពឹងម្តាយ នេះជារបៀបដែលសន្តីតេរេសាបានអញ្ជើញយើង ឲ្យធ្វើដំណើរជាមួយព្រះយេស៊ូ នៅក្នុងព្រះសហគមន៍ ហើយនេះ ក៏ជារបៀបដែលព្រះនាងម៉ារីបានធ្វើដំណើររួមជាមួយព្រះយេស៊ូដែរ។ សម្រាប់សន្តីតេរេសា ព្រះនាងម៉ារីគឺជាម្តាយ ជាគ្រីស្តបរិស័ទមុនគេបង្អស់ ដែលធ្វើដំណើរជាមួយយើង ព្រះនាងម៉ារីក៏រស់នៅក្នុងជំនឿជាមួយយើង ព្រះនាងម៉ារី អញ្ជើញយើងឲ្យមានចិត្តធម៌មេត្តាករុណា ព្រះនាងម៉ារីជួយណែនាំឲ្យយើងដើរតាមផ្លូវតូចតាច ដើម្បីស្គាល់ព្រះយេស៊ូ ដើម្បីធ្វើជាសាក្សី នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដមែន។

ក្នុងពាក្យកំណាព្យរបស់សន្តីតេរេសា បីខែមុនគាត់ទទួលមរណភាព មានចែងថា៖ "បន្តិចទៀតខ្ញុំមានអំណរសប្បាយពេញទី បន្តិចទៀតខ្ញុំទៅស្ថានបរមសុខ នៅទីនោះ ខ្ញុំនឹងឃើញព្រះនាងម៉ារីដែលញញឹមដាក់ខ្ញុំ នៅទីនោះខ្ញុំនឹងមានអំណរសប្បាយរួមជាមួយព្រះនាងម៉ារី ហើយខ្ញុំនឹងអង្គុយជាមួយព្រះនាង ដើម្បីរៀបរាប់ថ្វាយព្រះនាងថា ហេតុអ្វីបានជាខ្ញុំស្រឡាញ់ព្រះនាង និងខ្ញុំចង់ប្រាប់ព្រះនាងម្តងទៀតថា ខ្ញុំជាកូនរបស់ព្រះនាងពិតមែន"។ អាម៉ែន។












អាលេលូយ៉ា!





# សន្តី តេរេសា
# និង គ្រួសារ (ផ្សារតូច ពេលព្រឹក)

សន្តីតេរេសា បានមកដល់ប្រទេសកម្ពុជាយើងពីម្សិលមិញ ណែនាំឲ្យព្រះសហគមន៍យើងមានអំណរសប្បាយ។ សន្តីតេរេសា មានបំណងចង់ធ្វើដំណើរជុំវិញពិភពលោកទាំងមូល តាំងពីគាត់នៅអារាមកាមែលម្ល៉េះ។ ក្រោយមក តាមរយៈលោកបូជាចារ្យជាសាសនទូតនៅទ្វីបអាហ្វ្រិក និងលោកម្នាក់ទៀតនៅប្រទេសចិនបានផ្តួចផ្តើមឡើងនោះ ទើបសន្តីតេរេសាអាចធ្វើដំណើរទៅទូទាំងពិភពលោកទាំងមូលបាន ជាពិសេសមកដល់ប្រទេសកម្ពុជាយើង ដែលជាឱកាសមួយ ឲ្យគាត់បានមកដល់ភូមិភាគអាស៊ីអាគ្នេយ៍ ដែលគាត់ចង់មកជាយូរហើយ។ ពេលនេះ ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសកម្ពុជាយើងនឹងបានទទួលព្រះអំណោយទានយ៉ាងច្រើនថែមទៀត តាមរយៈសន្តីតេរេសា ដើម្បីឲ្យយើងបន្តកសាងព្រះសហគមន៍យ៉ាងពិសេស នៅក្នុងឆ្នាំនៃជំនឿនេះ។

រយៈពេលមួយអាទិត្យ ចាប់ពីថ្ងៃនេះទៅ សន្តីតេរេសានឹងដើរក្នុងភូមិភាគភ្នំពេញ ណែនាំព្រះសហគមន៍នីមួយឲ្យគិតពីចំណុចសំខាន់មួយរបស់គាត់។ យប់នេះខ្ញុំសូមនិយាយអំពីសន្តីតេរេសានិងក្រុមគ្រួសារ ដោយសារថ្ងៃនេះមានធាតុរបស់លូីហ្សេលី និងជាឪពុកម្តាយរបស់គាត់តាំងនៅទីនេះដែរ។ ហ្សេលី និងលូី សម្រេចចិត្តទទួលគ្នាជាប្តីប្រពន្ធ ដោយយកព្រះជាម្ចាស់ជាអាទិភាពនៅក្នុងជីវិតរបស់ពួកគាត់។ លូី មានរបៀបរស់នៅយ៉ាងស្ងៀមស្ងាត់តាំងពីដើមមកពីមុនគាត់មានបំណងថានឹងបួស ឯ ហ្សេលី វិញ គាត់ជាអ្នកគោរពប្រណិប័តន៍

ព្រះជាម្ចាស់តាំងពីដើមរៀងមកដែរ។ ពេលរស់នៅជាប្ដីប្រពន្ធ ពួកគាត់បានយកព្រះជាម្ចាស់ជាគ្រឹះនៃក្រុមគ្រួសារ ដែលពួកគាត់បានបង្កើត។ ពួកគាត់ជឿថា ព្រះបិតាស្រឡាញ់មនុស្សយើង ណែនាំឲ្យមនុស្សយើងទទួលសុភមង្គលនៅស្ថានបរមសុខរួមជាមួយព្រះអង្គ។ តាមទស្សនៈនេះ ពួកគាត់ខិតខំរស់នៅយ៉ាងល្អ ដើម្បីឆ្លើយតបនឹងសេចក្ដីស្រឡាញ់របស់ព្រះអង្គដូចជា៖

ទីមួយ តាមរយៈការងារ។ ជាធម្មតាឪពុកម្ដាយមានតួនាទីចិញ្ចឹមក្រុមគ្រួសារ។ ហ្សេលី ជាអ្នកប៉ាក់ក្រណាត់ និងល្វី ជាជាងនាឡិកា ពួកគាត់យកចិត្តទុកដាក់ចំពោះការងាររបស់ខ្លួនយ៉ាងខ្លាំង ដោយប្រមូលអារម្មណ៍ធ្វើការងារនោះយ៉ាងស្វិតស្វាញ ដើម្បីឲ្យមានលទ្ធផលល្អទទួលបានកម្រៃទុកចិញ្ចឹមគ្រួសារ និងម្យ៉ាងវិញទៀត ចំពោះការទទួលស្វាគមន៍កូនៗវិញ គឺពួកគាត់មានកូនស្រី៥នាក់ ហើយមានកូន៤នាក់ទៀតបានស្លាប់ពេលគេទើបនឹងកើត។ ពួកគាត់បំពេញតួនាទីជាឪពុកម្ដាយ ដោយទទួលស្វាគមន៍ជីវិត គឺទទួលកូនៗទាំង៩នាក់ នៅក្នុងសេចក្ដីស្រឡាញ់ អំណរសប្បាយ ដែលជាព្រះអំណោយទានពីព្រះជាម្ចាស់។ ពួកគាត់ខិតខំចិញ្ចឹមកូនទាំង៥នាក់ ដោយចិត្តអត់ធ្មត់ ដ្បិតកាលនៅពីក្មេង សន្ដីតេរេសាក៏របិលរប៉ូចយ៉ាងខ្លាំងដែរ ប៉ុន្តែទាំងម្ដាយទាំងឪពុកខិតខំណែនាំកូនដោយសេចក្ដីស្រឡាញ់ ណែនាំឲ្យកូនមានសេរីភាពដ៏ពេញលក្ខណៈនៅពេលអនាគត។ ហ្សេលីបានសរសេរអំពីម៉ារី ជាកូនស្រីម្នាក់របស់គាត់ថា៖ "យើងសង្ឃឹមថា ម៉ារីនឹងក្លាយទៅជាបងស្រី តែខ្ញុំមិនហ៊ានប្រាប់កូនទេ ដោយសារខ្ញុំចង់ទុកសេរីភាពឲ្យកូន ចង់ឲ្យកូនធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយខ្លួនឯង មិនមែនតាមចិត្តរបស់ខ្ញុំទេ"។ នេះជារបៀបដែលហ្សេលីជាម្ដាយយកចិត្តទុកដាក់អប់រំកូន ដោយរក្សាសេរីភាពរបស់កូន ដើម្បីឲ្យកូនរៀបចំអនាគត តាមគម្រោងការរបស់ព្រះជាម្ចាស់។

ហ្សេលី និង ល្វី ទាំងពីរនាក់កើតទុក្ខយ៉ាងខ្លាំង ពេលកូន៤នាក់បានស្លាប់។ ក្រុមគ្រួសារទាំងមូល ក៏កើតទុក្ខយ៉ាងធ្ងន់ធ្ងរដែរ នៅពេលហ្សេលីទទួលមរណភាព

និងនៅពេលល្វី មានជំងឺវង្វេងស្មារតីបន្តិចម្តងៗ។ ដូច្នេះ ក្រុមគ្រួសារនេះជួប ទុក្ខលំបាកខ្លាំងណាស់ ប៉ុន្តែ ពួកគេទទួលទុក្ខលំបាកទាំងនោះ នៅក្នុងជំនឿ។ ក្រុមគ្រួសារនេះ ចេះជួយគ្នាទៅវិញទៅមក ដើម្បីឈ្នះឧបសគ្គ ដោយទុកចិត្ត ទាំងស្រុងលើព្រះជាម្ចាស់។ មានចំណុចមួយដែលសំខាន់មែនទែន គឺជារៀង រាល់ថ្ងៃ ហ្សេលី និងល្វី តែងយកចិត្តទុកដាក់ក្នុងការអធិដ្ឋាន យកចិត្តទុកដាក់ ចូលរួមថ្វាយអភិបូជា និងទទួលព្រះកាយព្រះគ្រីស្ត។ ចំណុចមួយទៀត គឺពួក គាត់មិនមានចិត្តចង្អៀតចង្អល់ទេ ទោះបីមានកូនច្រើន តែពួកគាត់នៅតែយក ចិត្តទុកដាក់ចែករំលែកនូវអ្វីដែលពួកគាត់មាន ដល់អ្នកក្រីក្រ អ្នកតូចតាចដែរ។ ហ្សេលីមានសុបិន្តមួយថា កូនរបស់គាត់នឹងទៅជាសន្តិបុគ្គល ហេតុដូច្នេះហើយ ពួកគាត់យកចិត្តទុកដាក់អស់ពីសមត្ថភាព ណែនាំឲ្យកូនបានស្គាល់ព្រះយេស៊ូ ស្គាល់ព្រះនាងម៉ារី និងចេះធ្វើដំណើរនៅក្នុងព្រះសហគមន៍ដែលជាមហាគ្រួសារ របស់អ្នកជឿ។

ចំពោះសន្តីតេរេសាវិញ បានបង្ហាញច្រើនដងឲ្យឃើញថា គាត់បានទទួល ការណែនាំពីម្តាយ ឲ្យគាត់ចេះអធិដ្ឋាន ចេះស្រឡាញ់ព្រះយេស៊ូ ឲ្យគាត់បង្កើត ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះនាងម៉ារីដែលគាត់សូមធ្វើជាម្តាយ តាម រយៈការអធិដ្ឋាន ឲ្យគាត់ស្រឡាញ់ព្រះជាម្ចាស់ ហើយគាត់ក៏បានទទួលសេចក្តី ស្រឡាញ់ដ៏ទូលំទូលាយពីព្រះអង្គវិញដែរ។ នេះជារបៀបថែរក្សាក្រុមគ្រួសារ ទាំងមូលរបស់ហ្សេលី និង ល្វី ណែនាំឲ្យក្រុមគ្រួសារទៅជាគ្រួសារដ៏សុខសាន្ត នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ក្រុមគ្រួសារនេះជាក្រុមគ្រួសារគំរូ របស់យើងទាំងអស់គ្នា។

ថ្ងៃនេះ យើងរួមគ្នាស្វាគមន៍ធាតុសន្តីតេរេសា ហ្សេលី និង ល្វី ដែលពោរ ពេញដោយសុភមង្គល ដែលនាំឲ្យគ្រីស្តបរិស័ទយើង គិតពិចារណាអំពីក្រុម គ្រួសាររបស់ខ្លួន ឲ្យយើងរកឃើញគំរូមួយ មកជំរុញក្រុមគ្រួសាររបស់ខ្លួននីមួយៗ ក្នុងគោលដៅតែមួយ គឺណែនាំឲ្យក្រុមគ្រួសាររបស់យើង ទៅជាគ្រួសារដ៏វិសុទ្ធ

ដូចហ្សេលី និង លូី បានធ្វើរួចទៅហើយដែរ។ តើពេលនេះ យើងរកឃើញអំណរសប្បាយអ្វីខ្លះសម្រាប់ក្រុមគ្រួសាររបស់យើង? តើយើងទទួលស្គាល់ថា ព្រះសហគមន៍ជាក្រុមគ្រួសាររបស់យើងដែរឬទេ? សូមកុំគិតតែពីក្រុមគ្រួសាររបស់ខ្លួនតែប៉ុណ្ណោះ ឲ្យយើងយល់ថា ព្រះសហគមន៍ក៏ជាក្រុមគ្រួសាររបស់យើងដែរ។

ថ្ងៃនេះ យើងយល់អំពីសេចក្តីស្រឡាញ់ ដែលយើងត្រូវមាននៅក្នុងក្រុមគ្រួសារ និងក្នុងព្រះសហគមន៍។ ដូច្នេះ យើងត្រូវការជំរុញថែមទៀត ដើម្បីបង្កើតព្រះសហគមន៍ ដែលជាក្រុមគ្រួសារមួយដ៏ពិសេសរបស់យើង។ យើងត្រូវតែសួរថា តើក្រុមគ្រួសាររបស់សន្តីតេរេសា បានធ្វើអ្វីខ្លះ ដើម្បីបង្កើតទៅជាក្រុមគ្រួសារមួយដ៏សុខសាន្ត? តើពួកគាត់អាចជួយយើងបានតាមរបៀបណា?។

ដូច្នេះបន្ទាប់ពីអភិបូជា យើងមានពេលដើម្បីអធិដ្ឋានទូលអង្វរព្រះជាម្ចាស់តាមរយៈសន្តីតេរេសា និងឪពុកម្តាយរបស់គាត់ ឲ្យក្រុមគ្រួសាររបស់យើងផ្លាស់ទៅជាក្រុមគ្រួសារដ៏សុខសាន្ត ឲ្យគ្រួសារនីមួយៗនៅក្នុងប្រទេសកម្ពុជាយើងរកឃើញផ្លូវនៃសុភមង្គល និងឲ្យព្រះសហគមន៍របស់យើង ទៅជាក្រុមគ្រួសារដ៏ជាទីស្រឡាញ់របស់យើងយ៉ាងពិតប្រាកដមែន។ អាម៉ែន។

# សន្តី តេរេសា
# និង ការត្រាស់ហៅ ( ផ្ការតូច ពេលយប់ )

ថ្ងៃនេះយើងមានអំណរសប្បាយ ដោយបានមកគោរពធាតុសន្តីតេរេសាជាមួយគ្នា មានក្រុមអេម៉ាណូអែល សាម៉ូអែល មីកាអែលដែរ ដើម្បីបន្តអធិដ្ឋានរិះគិតអំពីការត្រាស់ហៅ និងមើលពីរបៀបដែលសន្តីតេរេសាបានរកឃើញការត្រាស់ហៅនៅក្នុងជីវិតរបស់គាត់។ នៅប្រទេសបារាំងគេមិនបូជាសពទេ សន្តីតេរេសាទទួលមរណភាពប្រហែល១១៥ឆ្នាំហើយ។ គេបានរំលែកធាតុរបស់គាត់ជាពីរចំណែក មួយចំណែកតម្កល់ទុកនៅលីស៊ីយើ ក្នុងអារាមកាមែល។ កាលពីឆ្នាំ១៩៩៧ ជាខួប១០០ឆ្នាំដែលគាត់បានទទួលមរណភាព ពេលនោះលោកអភិបាលនៅប្រទេសប្រេស៊ីលបានសម្រេចចិត្តយកធាតុមួយចំណែកទៀតរបស់គាត់មកដាក់ក្នុងកោដ្ឋមួយផ្សេងទៀត ដើម្បីឲ្យសន្តីតេរេសាធ្វើដំណើរតាមបំណងដែលគាត់ចង់ស្គាល់ និងចង់ដើរជុំវិញពិភពលោកទាំងមូល។

នៅពេលគេបង្កើតអារាមកាម៉ែលនៅហូជីមិញ ប្រទេសវៀតណាម ពេលនោះសន្តីតេរេសាចង់មកចូលរួមណាស់ តែដោយសារសុខភាពខ្សោយពេក គាត់មិនបានមកទេ។ គាត់និយាយថា៖ "ទោះបីខ្ញុំធ្វើដំណើរទៅចូលរួមមិនបាន តែខ្ញុំចូលរួមដោយការអធិដ្ឋាន"។ សន្តីតេរេសាធ្លាប់អធិដ្ឋានសម្រាប់លោកបូជាចារ្យម្នាក់ជាសាសនទូតនៅអាហ្វ្រិក និងម្នាក់ទៀតនៅជាសាសនទូតនៅប្រទេសចិន។ ឥឡូវនេះ ១៦ឆ្នាំហើយ ដែលធាតុសន្តីតេរេសាបានធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយទៀត។ កាលពីខែមុនសន្តីតេរេសាបានធ្វើដំណើរទៅប្រទេសភីលីពីន តែពេលនេះគាត់កំពុងតែរួមអធិដ្ឋានជាមួយយើងនៅប្រទេសកម្ពុជា។ យើងសួរថា៖ "តើសន្តីតេរេសា រកឃើញការត្រាស់ហៅរបស់គាត់យ៉ាងដូចម្តេច ?"។

តាមពិត ការត្រាស់ហៅសន្តីតេរេសា មិនអាចដូចគ្នាទៅនឹងការត្រាស់ហៅរបស់មនុស្សឯទៀតបានទេ។ តែពេលនេះខ្ញុំរំឭកអំពីការត្រាស់ហៅរបស់គាត់ គឺដើម្បីជួយឲ្យយើងមានកម្លាំងថែមទៀតរិះគិតអំពីការត្រាស់ហៅរបស់ខ្លួនយើងម្នាក់ៗ។

សន្តីតេរេសាធ្វើដំណើរជាមួយព្រះយេស៊ូតាំងពីរនៅក្មេងដែលប្លែកពីយើង។ សូមកុំឲ្យយើងអស់សង្ឃឹមអំពីការប្លែកពីគ្នានេះ តែសូមឲ្យយើងចាប់អារម្មណ៍បន្ថែមទៀតអំពីការត្រាស់ហៅរបស់គាត់ ដែលណែនាំឲ្យយើងចាប់អារម្មណ៍អំពីការត្រាស់ហៅរបស់ខ្លួនយើង និងអំពីរបៀបដែលខ្លួនយើងត្រូវបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូ។ សន្តីតេរេសាបានសរសេរសៀវភៅមួយក្បាលឈ្មោះថា៖ "ប្រវិត្តនៃព្រលឹងមួយ" ដែលនិយាយអំពីអនុស្សាវរីយ៍របស់គាត់ជាមួយព្រះយេស៊ូតាំងពីគាត់នៅក្មេងមកគឺ៖

ចំណុចទីមួយ ពេលសន្តីតេរេសាមានអាយុ៩ឆ្នាំ គាត់ដឹងយ៉ាងច្បាស់អំពីការត្រាស់ហៅ។ ពេលនោះគាត់បានទៅជួបបងស្រីប្រធានអារាមកាម៉ែល ដែលនិយាយប្រាប់គាត់ខ្លះៗអំពីជីវិតរបស់អ្នកបួស។ តេរេសាបានសរសេរថា៖ "ពេលខ្ញុំបានស្គាល់អំពីជីវិតនៅក្នុងអារាមកាម៉ែល នោះខ្ញុំយល់ថាអស្ចារ្យណាស់ ខ្ញុំមានអារម្មណ៍ថានៅក្នុងវាលរហោស្ថាននៃអារាមកាម៉ែល នោះខ្ញុំនឹងឃើញព្រះជាម្ចាស់ដ៏ពិតប្រាកដ ខ្ញុំចង់នៅរស់នៅកន្លែងនោះមែនទែន ដើម្បីជួបជាមួយព្រះយេស៊ូផ្ទាល់។ ខ្ញុំចង់រកឃើញសេចក្តីសុខនៅក្នុងវិញ្ញាណ និងព្រលឹងរបស់ខ្ញុំ"។

ចំណុចទីពីរ សន្តីតេរេសាបានទទួលព្រះកាយព្រះគ្រីស្តលើកដំបូង នៅអាយុ ១១ឆ្នាំ។ គាត់សរសេរថា៖ "ពេលទទួលព្រះកាយព្រះគ្រីស្តលើកដំបូងនោះហាក់បីដូចជាព្រះជាម្ចាស់យាងមកថើបនាងខ្ញុំនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ។ នាងខ្ញុំយល់ថា ព្រះអង្គស្រឡាញ់នាងខ្ញុំយ៉ាងខ្លាំង ហើយនាងខ្ញុំក៏ទូលទៅព្រះអង្គវិញថា នាងខ្ញុំក៏ស្រឡាញ់ព្រះអង្គយ៉ាងខ្លាំងណាស់ដែរ នាងខ្ញុំចង់បូជាជីវិតថ្វាយព្រះអង្គណាស់"។

បរិយាកាសនៅក្នុងក្រុមគ្រួសាររបស់សន្តីតេរេសា ណែនាំឲ្យគាត់ធ្វើដំណើរជាមួយព្រះយេស៊ូតាំងពីនៅវ័យក្មេង ដូច្នេះគ្រប់ដំណាក់កាលនៃជីវិត គាត់មានឱកាសជួបជាមួយព្រះយេស៊ូម្តងហើយម្តងទៀត គាត់មានបពិសោធន៍មួយដ៏អស្ចារ្យ គឺព្រះយេស៊ូយាងមកនៅក្នុងជីវិតរបស់គាត់ នៅពេលគាត់ទទួលព្រះកាយលើកដំបូង។ ចំពោះយើងវិញ ពេលទទួលព្រះកាយព្រះគ្រីស្ត តើយើងមានអំណរសប្បាយដល់កម្រិតណា? តើពេលនោះយើងដឹងថា ព្រះយេស៊ូយាងមកជួបយើងដោយផ្ទាល់ឬទេ?។ សម័យសន្តីតេរេសា គ្រីស្តបរិស័ទមិនសូវបានទទួលព្រះកាយព្រះគ្រីស្តប៉ុន្មានទេ ដោយសារព្រះសហគមន៍មានវិន័យតឹងរ៉ឹង គឺមុននឹងទទួលព្រះកាយគ្រីស្ត គ្រប់គ្នាត្រូវតែទទួលអគ្គសញ្ញាលើកលែងទោសយ៉ាងច្បាស់លាស់សិន។ សម្រាប់យើងដូច្នោះដែរ ពេលទទួលព្រះកាយព្រះគ្រីស្ត យើងត្រូវយល់ថាជាពេលមួយយ៉ាងពិសេស ដូច្នេះយើងត្រូវតែជម្រះចិត្តឲ្យបានស្អាតមុនពេលនឹងទទួលព្រះអង្គ ព្រោះជាពេលដែលព្រះយេស៊ូយាងមកនៅក្នុងជីវិតរបស់យើង ជាពេលដែលព្រះជាម្ចាស់ថើបយើងក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ។

ដំណាក់កាលទីបី នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត្រឆ្នាំ១៨៨៦ សន្តីតេរេសាបានទទួលព្រះអំណោយទានយ៉ាងពិសេសពីព្រះជាម្ចាស់។ ពេលនោះ គាត់អាយុ ១៤ឆ្នាំ ចូលក្នុងវ័យជំទង់ ចូលទៅក្នុងជីវិតថ្មីដែលជិតស្និទ្ធជាមួយព្រះជាម្ចាស់ និងដែលចេះទទួលស្គាល់អំពីចំណុចខ្សោយនឹងចំណុចល្អរបស់ខ្លួន។ នៅយប់បុណ្យព្រះយេស៊ូប្រសូត្រឆ្នាំនោះ បន្ទាប់ពីមកពីអភិបូជាវិញ សន្តីតេរេសាបានទទួលអំណោយពីឪពុកដែលនិយាយមកគាត់ថា៖ "កូនសប្បាយចិត្តទេ តែនេះជាឆ្នាំចុងក្រោយដែលពុករៀបចំអំណោយសម្រាប់កូន"។ ពេលឮឪពុកនិយាយដូច្នេះ គាត់ចង់យំ គាត់នឹកដល់ម្តាយដែលបានស្លាប់កាលពី១០ឆ្នាំមុនទុកគាត់ឲ្យនៅកំព្រា។ គាត់ពិបាកចិត្តខ្លាំងណាស់ តែបានធ្វើឲ្យគាត់ភ្ញាក់ស្មារតីថាពេលនេះគាត់ធំហើយ។ គាត់បានសរសេរថា៖ នៅពេលនោះខ្ញុំយល់ថា ធម៌

មេត្តាករុណារបស់ព្រះជាម្ចាស់ បានចូលនៅក្នុងដួងចិត្តរបស់ខ្ញុំ ធ្វើឲ្យខ្ញុំមានអំណរសប្បាយ ហើយខ្ញុំក៏ត្រូវតែណែនាំឲ្យអ្នកដទៃទទួលអំណរសប្បាយនេះដែរ ខ្ញុំត្រូវតែគិតពីអ្នកដទៃ។ ខ្ញុំបានឮព្រះសូរសៀងរបស់ព្រះយេស៊ូពីលើឈើឆ្កាងមកថា ព្រះអង្គស្រេកទឹក ដែលណែនាំឲ្យខ្ញុំយល់ថាខ្លួនខ្ញុំមានបេសកម្មក្នុងព្រះសហគមន៍ដើម្បីសង្គ្រោះមនុស្សលោក។ ខ្ញុំនៅទីនេះដើម្បីសង្គ្រោះមនុស្សពិសេសអ្នកបាបឲ្យគេមានជីវិតថ្មី"។

ក្រោយមក មានឃាតករម្នាក់ត្រូវគេកាត់ទោសប្រហារជីវិត ព្រោះបានសម្លាប់មនុស្សបីនាក់។ ពេលសន្តីតេរេសាដឹងរឿងនេះ គាត់ក៏បានអធិដ្ឋានឲ្យចោរនោះប្រែចិត្តសារភាពបាប។ មុនពេលគេកាត់ក មានលោកបូជាចារ្យម្នាក់ចូលទៅជិតឃាតករនោះហើយបង្ហាញព្រះឈើឆ្កាង ពេលនោះឃាតករបានយកឈើឆ្កាងមកថើបទាំងសារភាពបាប។ ពេលសន្តីតេរេសាអានព័ត៌មាននេះ គាត់រំភើបចិត្តយ៉ាងខ្លាំង និងយល់ថា ការអធិដ្ឋានរបស់គាត់មានប្រសិទ្ធិភាពហើយ។ ពេលសន្តីតេរេសាធ្វើដំណើរទៅទីក្រុងរ៉ូម សុំការអនុញ្ញាតចូលនៅក្នុងអារាម ពេលនោះគាត់យល់ថា រូបគាត់ត្រូវតែអធិដ្ឋានសម្រាប់បូជាចារ្យដែរ។ គាត់ត្រូវរកកន្លែង រកពេលដើម្បីនៅជាមួយព្រះយេស៊ូ និងអធិដ្ឋានសម្រាប់អ្នកមានបាបនិងបូជាចារ្យ នេះជាហេតុណែនាំឲ្យគាត់ចូលអារាមកាម៉ែលនៅអាយុ ១៥ឆ្នាំ។

ការត្រាស់ហៅរបស់គាត់ជ្រៅៗទៅ គាត់ផ្ញើជីវិតទាំងស្រុងទៅលើព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ គាត់យល់ថា ខ្លួនគាត់ជាយញ្ញដែលបូជាថ្វាយព្រះជាម្ចាស់។ គាត់ទូលអង្វរទៅព្រះជាម្ចាស់ សូមទៅជាមរណសាក្សីនៃសេចក្ដីស្រឡាញ់របស់ព្រះអង្គ គាត់ចង់ធ្វើជាបូជាចារ្យ ចង់ធ្វើជាព្យាការី ចង់ធ្វើជាគ្រីស្តទូត... ប៉ុន្តែ ពេលគាត់អានអត្ថបទរបស់សន្តៈប៉ូលដែលចែងថា៖ "សេចក្ដីស្រឡាញ់ធំលើសអ្វីៗទាំងអស់ ទោះបីខ្ញុំប្រកាសដំណឹងល្អក្តី ទោះបីខ្ញុំធ្វើការអស្ចារ្យក្តី ប្រសិនបើខ្ញុំគ្មានសេចក្តីស្រឡាញ់ទេ អ្វីៗទាំងអស់ដែលខ្ញុំធ្វើគឺគ្មានន័យទាល់តែសោះ" ពេលនោះគាត់ភ្ញាក់ស្មារតីហើយគាត់សរសេរថា៖ "នៅក្នុង

ព្រះសហគមន៍ដែលជាមាតារបស់ខ្ញុំ ខ្ញុំជាសេចក្តីស្រឡាញ់" នេះជាកំពូលនៃការត្រាស់ហៅរបស់គាត់ ដែលធ្វើឲ្យគាត់មានអំណរសប្បាយយ៉ាងបរិបូរណ៍។

ប៉ុន្តែការត្រាស់ហៅ ជួនកាលក៏ជួបនឹងភាពងងឹតដែរ។ សន្តីតេរេសាមានទាំងអំណរសប្បាយ និងទុក្ខលំបាកដែរ។ គាត់សរសេរថា៖ "ឱព្រះយេស៊ូអើយ ហេតុម្តេចឡើយ ព្រះអង្គអនុញ្ញាតឲ្យមានភាពងងឹតនៅក្នុងព្រលឹងរបស់នាងខ្ញុំ?"។ ពីរបីឆ្នាំនៃជីវិតចុងក្រោយ គាត់មានការឈឺចុកចាប់ដោយសារជំងឺរបេង គាត់ចូលរួមថ្វាយអភិបូជាមិនបាន តែគាត់បានផ្ញើទុក្ខលំបាកទាំងអស់លើព្រះយេស៊ូ ដើម្បីឲ្យទុក្ខលំបាកនេះទៅជាពន្លឺមួយនៅក្នុងជីវិតរបស់គាត់។ កុំគិតថាការត្រាស់ហៅរបស់យើងស្រួលទាំងអស់ ជួនកាលយើងមានចម្ងល់ មានការសង្ស័យ មានឧបសគ្គ មានថ្ម ណែនាំឲ្យយើងឈឺ ប៉ុន្តែក្នុងភាពងងឹតទាំងនោះ យើងដឹងថាព្រះយេស៊ូគង់នៅជាមួយ ហើយយើងអាចទៅមុខបាន ដូចសន្តីតេរេសាបានសរសេរថា៖ "នៅក្នុងភាពងងឹត ខ្ញុំនៅតែប្រកាសជំនឿរបស់ខ្ញុំលើព្រះយេស៊ូ ពេលខ្ញុំអស់សង្ឃឹម ខ្ញុំនៅតែជឿលើព្រះយេស៊ូ ដែលណែនាំឲ្យខ្ញុំអាចទៅមុខបាន"។

ការត្រាស់ហៅអំពីការអធិដ្ឋាន និងការប្រកាសដំណឹងល្អរបស់សន្តីតេរេសាមានសរសេរនៅក្នុងសំបុត្រមួយយ៉ាងស្អាត ដែលគាត់បានផ្ញើទៅបងស្រីរបស់គាត់៖ "តាមពិតការអធិដ្ឋាន ការប្រកាសដំណឹងល្អវាជាប់គ្នាដូចព្រះបន្ទូលចែងថា ចូរអង្វរម្ចាស់ស្រែឲ្យចាត់អ្នកច្រូតមកក្នុងស្រែរបស់លោក "នេះមានន័យថា មិនមែនព្រះយេស៊ូមួយព្រះអង្គឯងទេ ដែលសង្គ្រោះមនុស្សលោក គឺព្រះអង្គត្រូវការបងប្អូនឯទៀតៗដើម្បីជួយព្រះអង្គ។ ថ្ងៃនេះនិងថ្ងៃស្អែក យើងនឹងអធិដ្ឋានសម្រាប់ការត្រាស់ហៅរួមជាមួយព្រះសហគមន៍សកល រួមជាមួយសន្តីតេរេសាដែលជាគំរូក្នុងការផ្ញើជីវិតលើព្រះជាម្ចាស់នៅក្នុងអំណរសប្បាយ នៅក្នុងទុក្ខលំបាក នៅក្នុងជីវិតសាមញ្ញរបស់គាត់ ជាពេលវេលាមួយដើម្បីទទួលកម្លាំងថ្មីដើម្បីស្តាប់ព្រះសូរសៀងព្រះជាម្ចាស់ថែមទៀត។

សរុបសេចក្តីមក ការត្រាស់ហៅរបស់សន្ដីតេរេសាជាផ្លូវដ៏តូចសម្រាប់វិញ្ញាណដ៏តូច បានណែនាំឲ្យមនុស្សរាប់លាននាក់ ជាង១០០ឆ្នាំកន្លងមក យកគាត់ជាគំរូ ជាមិត្តសម្លាញ់ធ្វើដំណើររួមជាមួយ។ សន្ដីតេរេសាដែលចង់ទៅជាសន្ដីបុគ្គល គឺដោយសារគាត់បានស្ដាប់តាមការអប់រំ និងការអធិដ្ឋានយ៉ាងច្រើនពីឪពុកម្ដាយ។ ពេលគាត់ប្រៀបធៀបខ្លួនជាមួយនឹងសន្ដីទាំងឡាយដែលបានធ្វើការអស្ចារ្យជាច្រើន នោះគាត់ដូចជាអស់សង្ឃឹម ដោយគិតថាគាត់មិនអាចធ្វើបាន ដូចសន្ដីបុគ្គលទាំងនោះទេ ព្រោះគាត់មិនអាចដើរទៅគ្រប់ទីកន្លែងបាន គាត់មិនអាចទៅជួយអ្នកក្រីក្របាន ដូច្នេះគាត់ក៏រកផ្លូវមួយដើម្បីឲ្យទៅជាសន្ដីបុគ្គលមួយរូបបាន គឺ៖ "ខ្ញុំត្រូវធ្វើដំណើរជាមួយព្រះយេស៊ូ"។ សន្ដីតេរេសាមានបទពិសោធន៍ថា នៅសម័យនេះគេឡើងទៅផ្ទះល្វែងខ្ពស់ៗនៅជាន់លើ ដោយប្រើជណ្ដើរយន្តឲ្យបានឆាប់ដល់ ដូច្នេះគាត់ក៏មានត្រូវមានជណ្ដើរយន្តទៅព្រះជាម្ចាស់ឲ្យបានឆាប់ដែរ គឺជាព្រះយេស៊ូ។ ផ្លូវដ៏តូចរបស់គាត់ គឺភ្ជាប់ជាមួយព្រះយេស៊ូ ដោយសុខចិត្តផ្ញើជីវិតទាំងស្រុងលើធម៌មេត្តាករុណារបស់ព្រះអង្គ។

ចំពោះយើង ដើម្បីយកព្រះយេស៊ូជាទីពឹង គឺត្រូវមានវិញ្ញាណដ៏តូច (មិនលោភលន់ មិនចង់បានល្បីឈ្មោះ មិនគិតតែប្រយោជន៍ផ្ទាល់ខ្លួន) ឲ្យយើងដូចកូនក្មេងម្នាក់ដែលពឹងលើឪពុកម្ដាយ។ សន្ដីតេរេសាសរសេរថា៖ "ពេលខ្ញុំឡើងស្ថានបរមសុខ ខ្ញុំនឹងបាចផ្កាដើម្បីឲ្យបងប្អូនបានទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់"។ ចំពោះយើងដែលកំពុងគិតអំពីជីវិតជាគ្រីស្ដបរិស័ទ ឲ្យយើងរកឲ្យឃើញផ្លូវដ៏តូចមួយដូចសន្ដីតេរេសាដែរ។ ផ្លូវតូចតែមិនចង្អៀតសម្រាប់វិញ្ញាណដ៏តូចដែលសុខចិត្តយកព្រះយេស៊ូជាទីពឹង ដោយជឿថា ព្រះអង្គពិតជាផ្លូវដែលផ្ដល់សុភមង្គលពិតមែន។

មុនពេលទទួលមរណភាព សន្ដីតេរេសា មានប្រសាសន៍ថា៖ "ពេលខ្ញុំនៅស្ថានបរមសុខ ខ្ញុំនឹងធ្វើអំពើល្អនៅលើផែនដីនេះ"។ ពិតមែនជាង១០០ឆ្នាំ

ដែលសន្ដីតេរេសាបានទទួលមរណភាពទៅ គាត់បានធ្វើអំពើល្អយ៉ាងច្រើន មានមនុស្សជាច្រើននាក់បានទទួលជីវិតថ្មីដោយសារគាត់។ សព្វថ្ងៃយើងជឿថា សន្ដីតេរេសាកំពុងប្រព្រឹត្តតាមសេចក្ដីសង្ឃឹមរបស់គាត់ ដែលថា "ពេលខ្ញុំនៅស្ថានបរមសុខ ខ្ញុំនឹងធ្វើអំពើល្អនៅលើផែនដីនេះ"។

ខ្ញុំសូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ ក្នុងរយៈពេលបីអាទិត្យខាងមុខនេះ ពេលសន្ដីតេរេសាធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា សូមឲ្យគាត់មានឱកាសធ្វើអំពើល្អជាច្រើនសម្រាប់យើងខ្ញុំ សម្រាប់ព្រះសហគមន៍ និងសម្រាប់ប្រទេសកម្ពុជាទាំងមូល។ នៅព្រះសហគមន៍អារិយក្សត្រ ពេលសន្ដីតេរេសាជួបជាមួយព្រះនាងម៉ារីនៃទន្លេមេគ្គ នោះខ្ញុំបានអធិដ្ឋានសម្រាប់ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាយើង សូមព្រះជាម្ចាស់ប្រទានព្រះពរដល់យើង និងដល់ប្រជាជនកម្ពុជាទាំងមូល ឲ្យរួមជាមួយគ្នាធ្វើដំណើរនៅក្នុងសេចក្ដីសុខសាន្ដ និងសេចក្ដីស្រឡាញ់ដែលយើងទទួលបានពីព្រះយេស៊ូ។ អាម៉ែន។








ព្រះសហគមន៍កាតូលិក
CATHOLIC CHURCH



# សន្តី តេរេសា
# និង សេចក្តីស្រឡាញ់ (បឹងទំពុន)

ថ្ងៃនេះមានបងប្អូនយ៉ាងច្រើនមកដើម្បីអរព្រះគុណព្រះជាម្ចាស់។ យើងសប្បាយចិត្ត សូមស្វាគមន៍បងប្អូនដែលមកពីខេត្តនានាក្នុងភូមិភាគភ្នំពេញ និងក៏មានបងប្អូនខ្លះមកពីបាត់ដំបង និងមានខ្លះមកពីកំពង់ចាមដែរ។ យើងមានលោកឪពុកហ៊ានមកពីមណ្ឌលគិរីដែលឆ្ងាយជាងគេ។

ថ្ងៃនេះមហាគ្រួសាររបស់យើង មកជួបជុំគ្នាដើម្បីអរព្រះគុណព្រះជាម្ចាស់ និងដើម្បីស្គាល់ថែមទៀតអំពីសន្តីតេរេសា និងក៏សូមឲ្យគាត់បំភ្លឺជីវិតរបស់យើងជាគ្រីស្តបរិស័ទដែរ។ ម្សិលម៉្ងៃនៅអរិយក្សត្រ ជាកន្លែងដែលយើងគោរពព្រះនាងម៉ារីនៃទន្លេមេគង្គ បន្ទាប់ពីថ្វាយអភិបូជាហើយ យើងបានយកធាតុសន្តីតេរេសាឡើងលើភ្នំដើម្បីជួបជាមួយព្រះនាងម៉ារី។ នៅទីនោះខ្ញុំបានអធិដ្ឋានប្រទានពរដល់ប្រទេសកម្ពុជាទាំងមូល ដល់ព្រះសហគមន៍ទាំងអស់តាមរយៈព្រះនាងម៉ារី និងសន្តីតេរេសា ឲ្យយើងបានទទួលសេចក្តីសុខសាន្តគ្រប់ៗគ្នា។

ម្សិលមិញពេលរសៀល យើងបានមកដល់ផ្សារតូច។ នៅទីនោះយើងមានពេលវេលាច្រើន ជួបជាមួយនឹងយុវជន យុវនារី ដើម្បីរិះគិតអំពីរបៀបដែលសន្តីតេរេសាបានទទួលការត្រាស់ហៅ ដែលជួយបំភ្លឺពួកគេឲ្យគិតពីការត្រាស់ហៅផ្ទាល់ខ្លួនពួកគេម្នាក់ៗ។ ពេលយប់នោះ យើងតម្កល់ធាតុសន្តីតេរេសា រួមជាមួយនឹងធាតុឪពុកម្តាយរបស់គាត់ដែរ។ សន្តីតេរេសាកើតចេញពីគ្រួសារមួយយ៉ាងពិសេស ដែលមានឪពុកឈ្មោះ លូវី និងម្តាយឈ្មោះ ហ្សេលី ដែលទាំងពីរនាក់សព្វថ្ងៃព្រះសហគមន៍ទទួលស្គាល់ថាជា "អ្នកមានសុភមង្គល" ជាដំណាក់

កាលទីមួយមុនទទួលស្គាល់ពួកគាត់ថាជា "សន្តៈ និងជាសន្តី" បុគ្គល។ ដោយសារហេតុនេះ ម្សិលមិញយើងក៏បានរិះគិតអំពីសន្តីតេរេសា និងក្រុមគ្រួសាររបស់គាត់ ដែលជួយផ្តល់ជាពន្លឺដល់ក្រុមគ្រួសាររបស់យើងនៅក្នុងព្រះសហគមន៍ដែរ។

ប៉ុន្តែព្រឹកនេះ យើងដូរប្រធានបទ មកគិតអំពីរបៀបដែលសន្តីតេរេសាបំភ្លឺយើងអំពីសេចក្តីស្រឡាញ់ គឺ "សន្តីតេរេសា និងសេចក្តីស្រឡាញ់"។ ប្រធានបទនេះ ត្រូវនឹងអត្ថបទព្រះគម្ពីរដែលយើងបានស្តាប់អំបាញ់មិញ ដែលព្រះយេស៊ូបានប្រទានធម៌វិន័យថ្មីគឺ៖ "អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" ដែលជាមូលដ្ឋានគ្រឹះនៃជីវិតរបស់សន្តីតេរេសា។ តាមអ្វីដែលសន្តីតេរេសាបានសរសេរអំពីជីវិតរបស់គាត់ជាមួយព្រះយេស៊ូ និងតាមលិខិតដែលគាត់បានសរសេរផ្ញើទៅបងស្រីរបស់គាត់ នោះខ្ញុំចង់បំភ្លឺដល់បងប្អូនអំពីសន្តីតេរេសា និងសេចក្តីស្រឡាញ់ ថាមានន័យយ៉ាងដូចម្តេច?។

ទីមួយ តាមសន្តីតេរេសាពាក្យថា "សេចក្តីស្រឡាញ់" គឺមានន័យថា ឲ្យយើងផ្ញើជីវិតរបស់យើងទៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដោយសម្លឹងមើលទៅព្រះយេស៊ូដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតនៃជំនឿរបស់យើង។ ពេលណាយើងសម្លឹងមើលព្រះយេស៊ូ នោះណែនាំឲ្យយើងផ្ញើជីវិតរបស់យើងទាំងស្រុងទៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ដូច្នេះយើងត្រូវសម្លឹងមើលទៅព្រះយេស៊ូដែលត្រូវគេឆ្កាង យើងត្រូវសម្លឹងមើលទៅជីវិតរបស់ព្រះអង្គតាមគម្ពីរដំណឹងល្អឲ្យដូចជាកូនក្មេងម្នាក់ដូច្នោះដែរ។ ម្សិលមិញខ្ញុំបានបំភ្លឺថា ផ្លូវដ៏តូចដែលសន្តីតេរេសាបានរៀបចំ ជាផ្លូវដ៏តូចសម្រាប់វិញ្ញាណដ៏តូច នេះមិនមានន័យថាយើងដើរតាមផ្លូវចង្អៀតចង្អល់ទេ តែមានន័យថា ឲ្យយើងទុកចិត្តលើព្រះជាម្ចាស់ដូចជាកូនក្មេងម្នាក់ដែលទុកចិត្តលើឪពុកម្តាយដូច្នោះដែរ គឺឲ្យយើងសុខចិត្តផ្ញើជីវិតរបស់យើងនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ នេះជាផ្លូវដែលសន្តីតេរេសាបានរៀបចំឲ្យយើង។ ផ្លូវនេះណែនាំឲ្យយើងត្រូវតែលះបង់ប្រយោជន៍ផ្ទាល់ខ្លួន លះបង់ចិត្តលោភលន់ និងអ្វីៗទាំងអស់ដែលរាំងផ្លូវមិនឲ្យយើង

ទៅជាមនុស្សតូចតាច ជាអ្នកក្រខ្សត់ដែលចេះដាក់ខ្លួន ដូចព្រះយេស៊ូមានព្រះបន្ទូលក្នុងព្រះគម្ពីរដំណឹងល្អ ឲ្យយើងប្រព្រឹត្តតាម។ សន្តីតេរេសាធ្លាប់មានប្រសាសន៍ថា៖ "ការលះបង់ជាផ្លែនៃសេចក្តីស្រឡាញ់ដ៏ឆ្ងាញ់ជាងគេ"។ ដូច្នេះបើយើងចង់ដើរតាមសេចក្តីស្រឡាញ់ដែលសន្តីតេរេសាបានបំភ្លឺយើង អំពីព្រះយេស៊ូ នោះគឺយើងត្រូវតែលះបង់។ ក្នុងការរស់នៅ ពេលណាយើងហ៊ានលះបង់អ្វីៗសម្រាប់អ្នកដទៃ នោះគឺជាសញ្ញាសម្គាល់ថា យើងកំពុងតែដើរតាមសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់បានប្រទានឲ្យយើងហើយ។ ដូច្នេះចំណុចទីមួយជាមូលដ្ឋានគ្រឹះ គឺឲ្យយើងស្ថិតស្ថេរនៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ ដោយយើងសម្លឹងមើលទៅព្រះយេស៊ូ និងដោយយើងទទួលយកសេចក្តីស្រឡាញ់ពីព្រះយេស៊ូ និងព្រះជាម្ចាស់ផ្ទាល់ មិនមែនទៅរកសេចក្តីស្រឡាញ់តាមលោកីយ៍ដែលណែនាំឲ្យយើងវង្វេងនោះទេ។

ទីពីរ "សេចក្តីស្រឡាញ់ដែលយើងទទួលពីព្រះជាម្ចាស់ ជាសេចក្តីស្រឡាញ់ដែលយើងអាចរកឃើញគ្រប់ពេលវេលា នៅក្នុងជីវិតដ៏សាមញ្ញរបស់យើង។ ជីវិតរបស់យើង ទៅជាឱកាសសម្រាប់បង្ហាញសេចក្តីស្រឡាញ់ និងផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះយេស៊ូ"។ ពេលសន្តីតេរេសាមានប្រសាសន៍ដូចនេះ មិនមានន័យថា យើងត្រូវតែធ្វើការអស្ចារ្យដើម្បីបង្ហាញថា យើងបានទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់នោះទេ តែគាត់ចង់មានប្រសាសន៍ថា គ្រប់សកម្មភាពដែលយើងធ្វើប្រចាំថ្ងៃ ទោះតូចតាចបំផុតក្តី ក៏ជាសកម្មភាពដែលមានតម្លៃដែរ ប្រសិនបើយើងបានបញ្ចូលសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ទៅក្នុងសកម្មភាពនោះ។ មិនមែនតែនៅពេលយើងចូលនៅក្នុងក្រុមមេត្តាករុណាដើម្បីជួយអ្នកដទៃ ទើបថាយើងបានធ្វើការអស្ចារ្យមួយនោះទេ។ តាមពិតសម្រាប់យើងម្នាក់ៗដែលជាគ្រីស្តបរិស័ទពីព្រឹកដល់យប់គ្រប់សកម្មភាពរបស់យើង ប្រសិនបើយើងបញ្ចូលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ នោះណែនាំឲ្យយើងធ្វើជាសាក្សីនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ

និងណែនាំឲ្យព្រះសហគមន៍យើងទទួលព្រះអំណោយទានថែមទៀតតាមរយៈយើង។

នៅក្នុងជីវិតរបស់សន្ដីតេរេសា ទោះបីគាត់រើសសំរាមមួយនៅតាមផ្លូវ គឺគាត់ធ្វើនៅក្នុងសេចក្ដីស្រឡាញ់ ដូច្នេះទោះបីជាសកម្មភាពតូចបំផុតក្ដី ក៏ទៅជាសក្ខីភាពអំពីសេចក្ដីស្រឡាញ់ដែលព្រះយេស៊ូស្រឡាញ់យើង និងណែនាំឲ្យព្រះសហគមន៍ទទួលអំណោយទានថែមទៀតពីព្រះជាម្ចាស់ដោយសារសកម្មភាពរបស់យើង។ ហេតុនេះហើយ ឲ្យយើងបន្ដគិតនៅពេលយើងមានសកម្មភាពណាមួយ គឺឲ្យយើងធ្វើសម្រាប់ព្រះយេស៊ូ ឲ្យយើងធ្វើដោយសារយើងទទួលសេចក្ដីស្រឡាញ់ពីព្រះយេស៊ូ។ ពេលយើងធ្វើដូចនេះ បន្ដិចម្ដងៗសេចក្ដីស្រឡាញ់ដែលយើងទទួលពីព្រះយេស៊ូចូលនៅក្នុងខ្លួនយើង និងហៀរចេញពីបេះដូងយើងទៅដល់បងប្អូនឯទៀតៗជាមិនខាន ហើយជាមូលហេតុដែលណែនាំឲ្យអ្នកដទៃភ្ញាក់ស្មារតីថា ហេតុអ្វីយើងសប្បាយចិត្តម្ល៉េះនៅគ្រប់សកម្មភាពរបស់យើង?។ តាមពិតយើងសប្បាយចិត្តដោយសារយើងធ្វើនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូដែលព្រះអង្គគង់នៅជាមួយយើង។ នេះជាអ្វីដែលសន្ដីតេរេសារំឭកយើង។

ទីបី "ឲ្យយើងស្រឡាញ់គ្នាជាបងប្អូនបង្កើត"។ សន្ដីតេរេសាបានយកអត្ថបទព្រះគម្ពីរខ្លះដូចជា ព្រះយេស៊ូអញ្ជើញយើងឲ្យស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន ព្រះយេស៊ូសូមកុំឲ្យយើងរង់ចាំទទួលសំណងពីអ្នកដែលគេបានខ្ចីអ្វីមួយពីយើង ប៉ុន្ដែឲ្យយើងរង់ចាំទទួលរង្វាន់ពីព្រះជាម្ចាស់វិញ។ សន្ដីតេរេសាមានប្រសាសន៍ដូចនេះ គឺផ្ទុយពីរបៀបដែលមនុស្សយើងបានគិត តែគាត់មានបំណងឲ្យយើងស្រឡាញ់គ្នាជាបងប្អូនបង្កើត ហេតុដូច្នេះហើយ ទើបគាត់នឹកឃើញដល់អត្ថបទគម្ពីរទាំងនេះ។ សន្ដីតេរេសាមានរបៀបបីយ៉ាង ដើម្បីជួយឲ្យយើងខិតខំស្រឡាញ់គ្នាជាបងប្អូនបង្កើតបាន។

ចំណុចទីមួយ ប្រសិនបើយើងមិនសូវស្រឡាញ់អ្នកដទៃ តើធ្វើដូចម្ដេចដើម្បីឲ្យយើងអាចស្រឡាញ់គេវិញបាន?។ សន្ដីតេរេសាមានបទពិសោធន៍អំពីរឿង

នេះ ដោយសារនៅក្នុងអារាមដែលគាត់រស់នៅ មានបងស្រីម្នាក់ដែលគាត់ហាក់ដូចជាស្អប់ខ្លាំងមែនទែន ប៉ុន្តែក្រោយមក បងស្រីតេរេសាយល់ថាគំនិតនេះខុសហើយ គាត់ត្រូវតែស្រឡាញ់បងស្រីនោះឲ្យដូចបងប្អូនបង្កើតវិញ។ ហេតុនេះហើយសន្តីតេរេសាបានខិតខំធ្វើអ្វីៗទាំងអស់ដើម្បីបម្រើបងស្រីនោះ ដូចជាលើកទឹកចិត្តគាត់ដោយពាក្យសម្តី ឬដោយញញឹមដាក់គាត់ ដើម្បីឲ្យគាត់មានអំណរសប្បាយនៅពេលដែលជួបគ្នានឹងសន្តីតេរេសា។ ក្រោយពេល សន្តីតេរេសាទទួលមរណភាព បងស្រីនោះបានអានអត្ថបទដែលសន្តីតេរេសាបានសរសេរទុក ហើយគាត់ភ្ញាក់ស្មារតីដោយដឹងថា តាមពិតសន្តីតេរេសាស្រឡាញ់គាត់ជាងគេនៅក្នុងអារាម ណែនាំឲ្យគាត់គិតថា គាត់ជាបងស្រីជាទីស្រឡាញ់របស់សន្តីតេរេសា។ ដូច្នេះចំពោះយើងក៏ដូច្នោះដែរ គួរឲ្យយើងចាប់ផ្តើមតាមរបៀបនេះចំពោះមនុស្សណាដែលយើងមិនសូវស្រឡាញ់ ឲ្យយើងចាប់ផ្តើមស្រឡាញ់គេលើកទឹកចិត្តគេ ជួយគេ ដែលណែនាំឲ្យយើងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគេសាជាថ្មីវិញ ហើយគេក៏នឹងគិតថាយើងជាមិត្តដ៏ជាទីស្រឡាញ់របស់គេដែរ។

ចំណុចទីពីរ "នៅក្នុងសេចក្តីស្រឡាញ់ជាបងប្អូនបង្កើត កុំឲ្យយើងវិនិច្ឆ័យគេ"។ សន្តីតេរេសាធ្លាប់មានប្រសាសន៍ថា "នៅពេលដែលខ្ញុំគ្មាននិស្ស័យជាមួយនឹងមនុស្សណាម្នាក់ នោះខ្ញុំចង់វិនិច្ឆ័យគេនៅក្នុងរបៀបមិនល្អ" ប៉ុន្តែគាត់បន្ថែមថា "មុនយើងវិនិច្ឆ័យដល់ចំណុចខ្សោយគេ នោះឲ្យយើងវិនិច្ឆ័យនូវចំណុចល្អរបស់គេសិន" ដោយសារមនុស្សទាំងអស់ ទោះបីមនុស្សអាក្រក់ជាងគេក៏មានចំណុចល្អដែរ។ ដូច្នេះមុននឹងយើងវិនិច្ឆ័យនរណាម្នាក់ យើងត្រូវដឹងពីចំណុចល្អរបស់គេជាមុនសិន ទើបយើងអាចវាយតម្លៃនៅក្នុងសេចក្តីស្រឡាញ់បាន។

ចំណុចទីបី "នៅក្នុងសេចក្តីស្រឡាញ់ជាបងប្អូនបង្កើត គឺសូមឲ្យយើងស្រឡាញ់តាមរបៀបព្រះយេស៊ូ ឲ្យយើងស្រឡាញ់ដូចព្រះយេស៊ូ"។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"។ សន្តីតេរេសាមានប្រសាសន៍ថា៖ "នៅពេលខ្ញុំមានចិត្តមេត្តាករុណា

ខ្ញុំដឹងថានៅពេលនេះ គឺព្រះយេស៊ូកំពុងមានសកម្មភាពនៅក្នុងជីវិតរបស់ខ្ញុំ ហើយជាពេលដែលខ្ញុំជិតស្និទ្ធជាមួយព្រះអង្គខ្លាំងជាងគេ"។ ហេតុនេះ យើងត្រូវយល់អំពីរបៀបដែលព្រះយេស៊ូស្រឡាញ់ ដើម្បីឲ្យសេចក្តីស្រឡាញ់របស់យើងចាក់ឫសលើសេចក្តីស្រឡាញ់របស់ព្រះអង្គផ្ទាល់ ដែលមិនមែនចាក់ឫសលើកម្លាំងរបស់យើងផ្ទាល់នោះទេ។ សន្តីតេរេសាធ្លាប់រិះគិតអំពីបាបរបស់ខ្លួនគាត់ផ្ទាល់ថា៖ "ខ្ញុំមានបាបច្រើន ខ្ញុំជាមនុស្សទន់ខ្សោយ បើខ្ញុំស្រឡាញ់ដោយអំពើបាបរបស់ខ្ញុំ ឬចំណុចខ្សោយរបស់ខ្ញុំ នោះសេចក្តីស្រឡាញ់នឹងគ្មានន័យអ្វីសោះ។ តែទោះបីខ្ញុំជាមនុស្សម្នាក់ដែលមានអំពើបាប និងចំណុចខ្សោយក៏ដោយ ក៏ខ្ញុំដឹងថាព្រះយេស៊ូគង់នៅជាមួយខ្ញុំ ហើយព្រះជាម្ចាស់ក៏លើកលែងទោសឲ្យខ្ញុំដែរ។ ខ្ញុំដឹងថាសេចក្តីស្រឡាញ់របស់ព្រះយេស៊ូមានប្រសិទ្ធិភាពនៅក្នុងខ្លួនខ្ញុំ ណែនាំឲ្យខ្ញុំអាចស្រឡាញ់អ្នកដទៃបាន ហើយណែនាំឲ្យខ្ញុំជិតស្និទ្ធជាមួយព្រះអង្គដល់កម្រិតកំពូលបាន"។ ហេតុនេះហើយ អំពើបាបមិនមែនជាឧបសគ្គក្នុងការស្រឡាញ់អ្នកដទៃនោះទេ សំខាន់កុំឲ្យយើងស្រឡាញ់អ្នកដទៃដោយកម្លាំងរបស់យើងផ្ទាល់ តែឲ្យសេចក្តីស្រឡាញ់នោះចេញពីព្រះជាម្ចាស់ ដោយសារយើងបានអង្គុយសម្លឹងមើល និងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយដឹងថាព្រះយេស៊ូស្រឡាញ់យើងយ៉ាងខ្លាំង ហើយណែនាំយើងឲ្យយើងទទួលធម៌មេត្តាករុណាពីព្រះជាម្ចាស់ ឲ្យយើងធ្វើដំណើរជាមួយព្រះអង្គ ធ្វើជាសាក្សីនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់អ្នកដទៃ។ ឲ្យយើងដឹងថាមូលហេតុអ្វីយើងស្រឡាញ់ព្រះជាម្ចាស់? ឲ្យយើងទុកសំណួរនេះសម្រាប់ជីវិតរបស់យើង។

តាមសន្តីតេរេសា និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើង គឺយើងស្រឡាញ់ព្រះជាម្ចាស់ដោយសារព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសណ្តោសសម្រាប់យើងម្នាក់ៗ។ អាម៉ែន។









# សន្តី តេរេសា
# និង ព្រះយេស៊ូ (ចំប៉ា)

ថ្ងៃនេះ យើងជួបជាមួយសន្តីតេរេសា ខ្ញុំចង់បង្ហាញជូនបងប្អូនអំពីទំនាក់ទំនងរវាងសន្តីតេរេសានឹងព្រះយេស៊ូ ហើយតាមរយៈទំនាក់ទំនងនេះ ណែនាំឲ្យយើងអាចបង្កើតទំនាក់ទំនងល្អជាមួយព្រះយេស៊ូបានដែរ។ យើងដឹងអំពីរបៀបដែលសន្តីតេរេសា បានបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូ តាមសៀវភៅមួយក្បាល ដែលសន្តីតេរេសាបានសរសេរបង្ហាញពីជីវិតរបស់គាត់ ជាមួយព្រះយេស៊ូ។ ក្នុងសៀវភៅនោះ សន្តីតេរេសាបានចាប់ផ្តើមសរសេរដោយបង្ហាញអំពីសួនច្បាររបស់ព្រះយេស៊ូ ដែលមានផ្កាជាច្រើនប្រភេទ ដូចជាផ្កាលីលី និងផ្កាកូឡាបជាដើម។ គាត់បានប្រៀបផ្កាទាំងពីរនោះថា ជាសន្តបុគ្គលយ៉ាងអស្ចារ្យ ប៉ុន្តែចំពោះរូបគាត់វិញ គ្រាន់តែជាមនុស្សតូចតាចម្នាក់ប៉ុណ្ណោះ ដែលមិនអាចប្រៀបធៀបជាមួយផ្កាទាំងពីរនោះបានទេ ប៉ុន្តែក៏មានផ្កាផ្សេងៗទៀត ដែលជាសន្តៈសន្តីបុគ្គលសាមញ្ញធម្មតាដូចគាត់ដែរ។

ពេលនេះ ប្រហែលសន្តីតេរេសា កំពុងតែមើលយើងពីស្ថានបរមសុខមក គាត់ឃើញសួនច្បាររបស់ព្រះយេស៊ូនៅក្នុងព្រះវិហារនេះ ដែលមានទាំងផ្កាពិសេសៗ និងផ្កាធម្មតាដែរ។ សន្តីតេរេសាមានបទពិសោធន៍យ៉ាងពិសេសលើកទីមួយជាមួយព្រះយេស៊ូ គឺនៅថ្ងៃដែលគាត់បានទទួលព្រះកាយព្រះគ្រីស្តជាលើកដំបូង នៅពេលនោះគាត់មានអាយុ៩ឆ្នាំ។ គាត់បានសរសេរថា៖ "នៅពេលខ្ញុំទទួលព្រះកាយព្រះគ្រីស្តលើកដំបូង ពេលនោះប្រៀបបីដូចជាព្រះយេស៊ូមកថើបខ្ញុំ ហើយណែនាំឲ្យខ្ញុំមានអំណរសប្បាយពេញទី។ ពេលព្រះកាយយាងចូលក្នុងខ្លួនខ្ញុំ នោះព្រះយេស៊ូគង់នៅជាមួយខ្ញុំតែម្តង"។ សេចក្តីនេះ នាំឲ្យយើងគិតអំពីរបៀបដែលយើងទទួលព្រះកាយព្រះគ្រីស្តដែរ តើពេលនោះ

យើងយល់ថា ព្រះយេស៊ូយាងចូលដោយផ្ទាល់ក្នុងរូបកាយយើងដែរឬទេ? តើយើងអាចមានរបៀបថ្មីបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូ ណែនាំឲ្យជីវិតរបស់យើងកាន់តែជិតស្និទ្ធជាមួយព្រះអង្គថែមទៀតដែរឬទេ?។

សន្តីតេរេសាបានរិះគិតថា តើធ្វើដូចម្តេចដើម្បីឲ្យទៅជាសន្តីបុគ្គលបាន?។ ថ្ងៃមួយពេលគាត់អានអត្ថបទគម្ពីរ ស្តីអំពីសេចក្តីស្រឡាញ់ ពេលនោះគាត់ភ្ញាក់ស្មារតីថា៖ "ប្រសិនបើខ្ញុំ ចង់ជាប់ជិតស្និទ្ធជាមួយព្រះយេស៊ូ ឬចង់ទៅជាសន្តីបុគ្គលពិតមែន នោះខ្ញុំត្រូវការតែម៉្យាង គឺទីពឹងទាំងស្រុងលើព្រះយេស៊ូ"។ គាត់យល់ឃើញថា៖ "ព្រះយេស៊ូនឹងចាប់ដៃខ្ញុំលើកឡើងទៅស្ថានបរមសុខ ដូច្នេះខ្ញុំត្រូវតែចាប់ព្រះហស្តរបស់ព្រះអង្គវិញឲ្យជាប់ ដើម្បីឡើងទៅជាមួយព្រះអង្គ"។ ចំពោះយើងក៏ដូច្នោះដែរ ដើម្បីចាប់ព្រះហស្តរបស់ព្រះយេស៊ូឲ្យបាន តើយើងត្រូវធ្វើយ៉ាងដូចម្តេច? សន្តីតេរេសា បានរកឃើញផ្លូវដ៏តូចមួយ ដើម្បីចាប់ព្រះហស្តរបស់ព្រះយេស៊ូឲ្យបាន គឺឲ្យយើងមានចិត្តគំនិតដូចកូនក្មេងម្នាក់ គឺកូនក្មេងដែលទីពឹង និងទុកចិត្តលើឪពុកម្តាយរបស់ខ្លួនទាំងស្រុង។ អំបាញ់មិញ យើងបានឃើញកូនក្មេងដែលពាក់អាវដូចសន្តីតេរេសា រាំ យើងបានឃើញពីរបៀបពួកគេសប្បាយចិត្ត ពួកគេមើលទៅអ្នកគ្រូរបស់ខ្លួនទាំងមិនភ័យខ្លាចអ្វីទេ ពួកគេមានអំណរសប្បាយនៅក្នុងកិច្ចការដែលពួកគេកំពុងធ្វើ នេះជារបៀបដែលកូនក្មេងមានអំណរ ដែលទុកចិត្តលើអ្នកគ្រូរបស់ខ្លួន។ ចំពោះយើងជាមួយព្រះយេស៊ូក៏ត្រូវតែដូចនេះដែរ គឺឲ្យយើងរៀបចំចិត្តគំនិតដោយដកចេញនូវចិត្តលោភលន់ ចិត្តប្រណែន។ ចូរឲ្យយើងមានចិត្តបរិសុទ្ធដូចកូនក្មេង ហើយនេះ ជាមូលហេតុដែលសន្តីតេរេសាបានរើសឈ្មោះថា៖ "សន្តីតេរេសានៃព្រះកុមារយេស៊ូ និងព្រះភ័ក្ត្ររបស់ព្រះអង្គ"។ ពេលយើងនិយាយអំពីព្រះភ័ក្ត្ររបស់ព្រះអង្គ នាំឲ្យយើងនឹកឃើញដល់សន្តីម៉ូនីកា ដែលយកក្រណាត់ទៅជូតព្រះភ័ក្ត្រព្រះយេស៊ូ ដែលមានញើស និងឈាម នៅពេលព្រះអង្គកំពុងរងទុក្ខលំបាក មុននឹងព្រះអង្គសោយព្រះទិវង្គត។

ដើម្បីដើរតាមព្រះយេស៊ូ យើងត្រូវតែលះបង់ចោលអ្វីៗទាំងអស់ និងធ្វើចិត្តឲ្យបរិសុទ្ធដូចកូនក្មេង ហើយត្រូវលីឈើឆ្កាងដូចព្រះយេស៊ូដែរ។ ក្នុងជីវិត

របស់យើង តែងលាយឡំដោយអំណរសប្បាយនិងទុក្ខលំបាក តែក្នុងជំនឿរបស់យើង ឈើឆ្កាងមានសារៈសំខាន់ណាស់ ដ្បិតយើងមិនអាចជួបនឹងព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ដោយមិនលីឈើឆ្កាងនោះទេ។ ដូច្នេះ ដើម្បីទៅជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ នោះយើងត្រូវតែលះបង់ចោលអ្វីៗទាំងអស់ និងត្រូវធ្វើចិត្តដូចកូនក្មេង និងត្រូវលីឈើឆ្កាងរបស់ខ្លួនដែរ។ ឈើឆ្កាងដែលធ្ងន់ជាងគេនៅក្នុងជីវិតរបស់យើង គឺអំពើបាបរបស់ខ្លួន។ សន្តីតេរេសាបានសរសេរថា៖ "ខ្ញុំយល់ថា ប្រសិនបើខ្ញុំសុខចិត្តប្រែចិត្ត ទោះបីខ្ញុំបានធ្វើអំពើបាបធ្ងន់ជាងគេ តែខ្ញុំដឹងថា ពេលខ្ញុំទៅជួបព្រះយេស៊ូ នោះព្រះអង្គមុខជានឹងទទួលស្វាគមន៍ខ្ញុំជានិច្ច។ ព្រះយេស៊ូជារៀមច្បងរបស់យើង ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ ព្រះអង្គធ្វើដំណើរជាមួយយើង នាំយើងឲ្យបានជួបនឹងព្រះបិតា"។ ចំពោះយើង តើយើងជឿថាព្រះយេស៊ូយាងមករំដោះយើងឲ្យរួចពីបាបដែរឬទេ? តើយើងជឿថា ដើម្បីធ្វើដំណើររួមជាមួយព្រះយេស៊ូ នោះយើងត្រូវតែលីឈើឆ្កាងមែនដែរឬទេ? តើយើងជឿថា ព្រះយេស៊ូណែនាំឲ្យជីវិតរបស់យើង មានអំណរសប្បាយដ៏ពេញលក្ខណៈដែរឬទេ?។ នេះជាសំណួរ ដែលសន្តីតេរេសាបានសួរមកយើងនៅថ្ងៃនេះ។ តែមានមួយសំណួរទៀតផងរបស់ខ្ញុំ ថាតើយើងសុខចិត្តផ្ញើជីវិតរបស់យើងទាំងស្រុង ទៅលើព្រះយេស៊ូ ដូចសន្តីតេរេសាដែរឬទេ?។

ចូរយើងទាំងអស់គ្នា ទុកសំណួរទាំងនេះនៅក្នុងដួងចិត្ត ទាំងពិចារណាហើយបន្ទាប់ពីថ្វាយអភិបូជានេះ យើងនឹងនាំគ្នាគោរពសន្តីតេរេសា ទាំងសួរខ្លួនឯងថា៖ "ជាគ្រីស្តបរិស័ទម្នាក់ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេចដើម្បីបានផ្ញើជីវិតរបស់ខ្ញុំទាំងស្រុងទៅលើព្រះយេស៊ូ ដូចសន្តីតេរេសា?"

ចូរយើងមានអំណរសប្បាយ ដោយយើងដឹងថា មានព្រះយេស៊ូគង់នៅជាមួយយើង មានព្រះជាម្ចាស់ស្រឡាញ់យើង។ ជ័យយោ សន្តីតេរេសា! ជ័យយោ ព្រះយេស៊ូ! ។ អាម៉ែន។








# សន្តី តេរេសា
# និង ការអធិដ្ឋាន (ក្រុងព្រះសីហនុ)

ថ្ងៃនេះ យើងជួបជុំគ្នាថ្វាយអភិបូជា ដោយមានវត្ថុមានធាតុសន្តីតេរេសាជាឱកាសមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់ចំពោះសន្តបុគ្គល សន្តីបុគ្គល និងជាពិសេសសម្រាប់សន្តីតេរេសា ដែលកំពុងនៅជាមួយយើង និងមើលយើងពីស្ថានបរមសុខមក និងកំពុងចែកព្រះអំណោយទានឲ្យយើងជាច្រើន។ សន្តីតេរេសាធ្លាប់មានប្រសាសន៍ថា៖ "ពីស្ថានបរមសុខ ខ្ញុំនឹងយកចិត្តទុកដាក់ធ្វើអំពើល្អនៅលើផែនដីនេះ"។ សន្តីតេរេសាបានទទួលមរណភាពតាំងពី១០០ឆ្នាំមកហើយ តាំងពីពេលនោះរហូតមកដល់ឥឡូវនេះ សន្តីតេរេសាតែងតែធ្វើអំពើល្អយ៉ាងច្រើនចំពោះមនុស្សទាំងអស់ ដែលបានសូមឲ្យគាត់ជួយទូលអង្វរទៅព្រះជាម្ចាស់ សម្រាប់ការប៉ងប្រាថ្នារបស់គេ។ ដូច្នេះ ពេលនេះជាឱកាសមួយដ៏ល្អសម្រាប់យើងនៅទីនេះ ដើម្បីអធិដ្ឋាននិងសូមព្រះពរពីព្រះជាម្ចាស់តាមរយៈសន្តីតេរេសាដែរ។

យប់នេះ ខ្ញុំចង់បំភ្លឺជូនបងប្អូនអំពីរបៀបដែលសន្តីតេរេសាបានអធិដ្ឋាន ព្រោះការអធិដ្ឋានជាកិច្ចការមួយសំខាន់ណាស់។ សន្តីតេរេសាទទួលផលផ្លែយ៉ាងច្រើននៅក្នុងជីវិតរបស់គាត់ ដោយសារការអធិដ្ឋាន។ សន្តីតេរេសាបានមានប្រសាសន៍ចេញពីបេះដូងរបស់គាត់ថា នៅពេលអធិដ្ឋាន គាត់បានសម្លឹងមើលទៅស្ថានបរមសុខ និងទៅព្រះជាម្ចាស់តែប៉ុណ្ណោះ។ ពេលអធិដ្ឋាន គាត់បានបង្កើតទំនាក់ទំនងជាមួយស្ថានបរមសុខដោយផ្ទាល់ ពេលនោះគាត់ប្រៀបដូចជាម្ចាស់ក្សត្រីមួយព្រះអង្គចូលគាល់ព្រះមហាក្សត្រ ទាំងទូលសូមព្រះមហាក្សត្រនូវអ្វីៗទាំងអស់ និងព្រះមហាក្សត្រក៏គាប់ព្រះហឫទ័យប្រទានមកម្ចាស់

ក្សត្រីតាមការទូលសូមទាំងអស់នោះដែរ។ នេះមានន័យថា ពេលអធិដ្ឋាន គឺជាពេលវេលាមួយដ៏ឱឡារិក ជាពេលណែនាំឲ្យយើងបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយដឹងថាយើងអាចសុំអ្វីៗទាំងអស់ពីព្រះអង្គបាន។

សន្តីតេរេសា មានប្រសាសន៍បន្ថែមទៀតថា៖ "ព្រះជាម្ចាស់ជាអ្នកមាន (មិនមែនមានលុយ) ហើយព្រះអង្គក៏សព្វព្រះហឫទ័យចែករំលែកដល់មនុស្សយើងម្នាក់ៗដែរ"។ របៀបទំនាក់ទំនងរបស់ព្រះជាម្ចាស់ ផ្សេងពីរបៀបរបស់មនុស្សយើង។ ឧទាហរណ៍ យើងមាន១០០០ដុល្លា យើងចែកឲ្យអ្នកក្រ ១០០០នាក់ គឺម្នាក់ៗទទួលបាន១ដុល្លា តែព្រះជាម្ចាស់ក្នុងម្នាក់ៗទទួលបាន ១០០០ដុល្លាដូចគ្នា។ នេះមានន័យថា អ្វីៗដែលព្រះជាម្ចាស់មាន នោះព្រះអង្គនឹងប្រទានឲ្យយើងទាំងអស់ ដូច្នេះពេលយើងអធិដ្ឋាន សូមកុំខ្លាចនឹងទូលសូម កុំឲ្យយើងបារម្ភថា ព្រះអង្គនឹងគ្មានអ្វីគ្រប់គ្រាន់សម្រាប់យើង ចូរទូលសូមព្រះជាម្ចាស់ទៅ ដោយដឹងថា ព្រះអង្គនឹងប្រទានឲ្យយើងនូវអ្វីៗទាំងអស់ដែលយើងទូលទៅព្រះអង្គ។

អធិដ្ឋាន ជាពេលមួយដើម្បីអរព្រះគុណព្រះជាម្ចាស់នូវគ្រប់កាលៈទេសៈនៃជីវិតរបស់យើងមានន័យថា យើងអរព្រះគុណព្រះអង្គទាំងនៅពេលយើងមានអំណរសប្បាយ និងនៅពេលយើងមានទុក្ខព្រួយដែរ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងការអធិដ្ឋានបែបនេះណាស់ ដោយឈ្វេងយល់ថាយើងបង្កើតទំនាក់ទំនងយ៉ាងពិសេសជាមួយព្រះអង្គ។ ហេតុនេះហើយពេលយើងអធិដ្ឋានយើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ ដោយផ្ញើជីវិតរបស់យើងទាំងស្រុងលើព្រះអង្គ គឺផ្ញើទាំងអំណរ ផ្ញើទាំងទុក្ខព្រួយរបស់យើង ដោយដឹងថាព្រះអង្គនឹងទទួលអ្វីៗទាំងអស់យើង។ សន្តីតេរេសាធ្លាប់មានប្រសាសន៍ថា៖ "នៅពេលយើងអរព្រះគុណព្រះជាម្ចាស់ម្តង ព្រះអង្គនឹងប្រទានពរឲ្យយើង១០ដង"។ ហេតុនេះហើយ កុំឲ្យយើងខ្លាច ចូរអរព្រះគុណព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ដោយដឹងថាព្រះអង្គនឹងប្រទានពរច្រើនដង គុណជា១០ដងមកយើង នេះជារបៀបដែល

សន្តីតេរេសា ណែនាំឲ្យយើងបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់នៅក្នុងការអធិដ្ឋាន។

អធិដ្ឋាន ជាពេលវេលាមួយ ដើម្បីឲ្យយើងអង្គុយ និងឲ្យយើងសន្ទនា ឲ្យយើងស្តាប់និងអរព្រះគុណព្រះជាម្ចាស់ ឲ្យយើងបង្កើតទំនាក់ទំនងជាមួយព្រះបិតាយ៉ាងជិតស្និទ្ធ។ ចូរដឹងថា ពេលអធិដ្ឋាន យើងត្រូវតែដូចកូនក្មេងម្នាក់ ព្រះបិតាស្រឡាញ់យើង ព្រះអង្គថែរក្សាយើង ចូរឲ្យយើងមានអំណរសប្បាយពេញទីពេលយើងអធិដ្ឋាន។ ប៉ុន្តែ ជួនកាលពេលអធិដ្ឋាន យើងមិនដឹងថានិយាយអ្វីទេ យើងអង្គុយ យើងស្ងាត់ ជួនកាលទៀតយើងបែរជានៅចំពោះព្រះភ័ក្ត្រព្រះបិតាគិតអំពីបញ្ហាផ្សេងៗ ដែលនាំឲ្យយើងទៅឆ្ងាយពីព្រះជាម្ចាស់វិញ។ ហេតុនេះហើយ សន្តីតេរេសា បានប្រាប់យើងអំពីការអធិដ្ឋានថា នៅពេលយើងអធិដ្ឋាន យើងគ្រាន់តែអង្គុយ ហើយយើងអានធម៌ឱព្រះបិតាដោយយឺតៗ រួចហើយយើងត្រូវគិតអំពីអ្វី ដែលយើងត្រូវទូលថ្វាយទៅព្រះអង្គ។ នៅពេលយើងអស់សង្ឃឹម នៅពេលយើងអស់កម្លាំង យើងមិនដឹងបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់យ៉ាងដូចម្តេចទេ ពេលនោះសូមឲ្យយើងអង្គុយ ឲ្យយើងយល់ថា ពិតមែនថ្ងៃនេះព្រះជាម្ចាស់មានវត្តមាននៅក្នុងជីវិតរបស់ខ្ញុំនោះបានហើយ។ ដូច្នេះសម្រាប់សន្តីតេរេសា ការអធិដ្ឋាន គឺទូលអង្វរព្រះយេស៊ូបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ អរព្រះគុណព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង។

ចុងក្រោយបំផុតសន្តីតេរេសា មានប្រសាសន៍ថា សូមឲ្យយើងទូលអង្វរព្រះបិតាសម្រាប់ខ្លួនយើងផ្ទាល់ផង និងសម្រាប់អ្នកដទៃផង។ អ្វីៗទាំងអស់ដែលយើងសូមសម្រាប់យើង ឲ្យយើងសូមសម្រាប់អ្នកដទៃដែរ។ បើធ្វើដូច្នេះការអធិដ្ឋានរបស់យើង នឹងទៅជាការអធិដ្ឋានសកល ដោយសារតែយើងលែងអង្វរព្រះជាម្ចាស់សម្រាប់តែខ្លួនឯង តែសម្រាប់បងប្អូនទាំងអស់នៅក្នុងពិភពលោកទាំងមូល។ ពេលយើងអធិដ្ឋាន សម្រាប់ក្រុមគ្រួសាររបស់យើងដែល

កំពុងរងទុក្ខលំបាក នោះយើងក៏ត្រូវតែនឹកដល់ក្រុមគ្រួសារទាំងអស់នៅក្នុងពិភពលោកទាំងមូល ដែលកំពុងតែមានបញ្ហាដែរ។

ដូច្នេះ ប្រសិនបើការអធិដ្ឋានរបស់យើងទូលំទូលាយបែបនេះ មានន័យថាការអធិដ្ឋានរបស់យើងនេះ ចូលនៅក្នុងបេះដូងរបស់ព្រះយេស៊ូ ដោយសារបេះដូងរបស់ព្រះអង្គទូលំទូលាយណាស់ ព្រះអង្គសព្វព្រះហឫទ័យទទួលបងប្អូនទាំងអស់។ ដូច្នេះយប់នេះ ដោយយើងមានសន្តិតេរេសានៅជាមួយ ចូរយើងយកពេលវេលានេះ ដើម្បីអធិដ្ឋានតាមរបៀបយ៉ាងសាមញ្ញ ដោយដឹងថាព្រះយេស៊ូគង់នៅជាមួយយើង ព្រះយេស៊ូធ្វើដំណើរជាមួយយើង ព្រះយេស៊ូស្រឡាញ់យើង និងសូមឲ្យសន្តិតេរេសាជួយយើង ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតដ៏ភ្លឺស្វាង ក្នុងពេលដែលយើងកំពុងធ្វើដំណើររួមជាមួយព្រះយេស៊ូនៅក្នុងលោកនេះនៅឡើយ។ អាម៉ែន។













# សន្តី តេរេសា
# និង ព្រះកាយព្រះគ្រីស្ទ (ជុំគីរី)

តាំងពីប៉ុន្មានថ្ងៃហើយ ពេលយើងធ្វើដំណើរជាមួយសន្តីតេរេសា នៅក្នុងភូមិភាគភ្នំពេញ យើងបានឃើញថាតាមព្រះសហគមន៍នីមួយៗរៀបចំការស្វាគមន៍យ៉ាងអស់ពីសមត្ថភាព។ នេះជាសញ្ញាសម្គាល់ដ៏ពិសេសមួយដែលបង្ហាញថា តាំងពីដើមរៀងមក សន្តីតេរេសាតែងតែប្រមូលគ្រីស្តបរិស័ទ ឲ្យជួបជុំគ្នាអធិដ្ឋាន ឲ្យរួមគ្នាអរព្រះគុណព្រះជាម្ចាស់ ដើម្បីឲ្យយើងជិតស្និទ្ធថែមទៀតជាមួយព្រះយេស៊ូ។

នៅក្នុងកោដ្ឋនេះ មានធាតុរបស់សន្តីតេរេសា។ ពេលធ្វើពិធីតែងតាំងគាត់ទៅជាសន្តី គេបានយកធាតុខ្លះមកដាក់ក្នុងកោដ្ឋនេះ សម្រាប់ធ្វើដំណើរជុំវិញពិភពលោកទាំងមូល និងយកធាតុខ្លះទៀតដាក់ក្នុងកោដ្ឋមួយផ្សេង តម្កល់នៅទីក្រុង លីស៊ីយើ នៅប្រទេសបារាំងដូចយើងបានឃើញនៅក្នុងវីដេអូរួចហើយ។ តាំងពីឆ្នាំ១៩៩៧ សន្តីតេរេសាបានធ្វើដំណើរទៅប្រទេសមួយចំនួននៅទ្វីបអាស៊ី ដូចជាហុងកុង តៃវ៉ាន់ និងភីលីពីន។ ពេលយើងមើលវីដេអូ ណែនាំឲ្យយើងដឹងថា សន្តីតេរេសាក្លាយទៅជាសន្តីម្នាក់ដោយសារគាត់បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ដោយសារគាត់បញ្ចូលសេចក្តីស្រឡាញ់ទៅក្នុងគ្រប់សកម្មភាពរស់នៅរបស់គាត់ ដោយសារគាត់ទុកចិត្តលើព្រះជាម្ចាស់ និងដោយសារគាត់មានចិត្តដូចកូនក្មេង។

ថ្ងៃនេះខ្ញុំចង់បង្ហាញអំពីសន្តីតេរេសា និងព្រះកាយព្រះគ្រីស្ត នៅទីនេះមាន

បងប្អូនមួយចំនួនដែលត្រៀមខ្លួនធ្វើជាគ្រីស្តបរិស័ទ ដូច្នេះជាឱកាសមួយ ដើម្បីយល់អំពីអត្ថន័យនៃព្រះកាយព្រះគ្រីស្ត សម្រាប់ជីវិតរបស់យើងជាគ្រីស្តបរិស័ទតាមរបៀបរបស់សន្តីតេរេសា។ សន្តីតេរេសាមានប្រសាសន៍ថា៖ "ក្នុងអភិបូជាពេលលោកបូជាចារ្យទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធឲ្យនំប៉័ងទៅជាព្រះកាយ ឲ្យស្រាទៅជាព្រះលោហិត នោះលោកមិនធ្វើដើម្បីទុកព្រះកាយឲ្យនៅក្នុងពែងនោះទេ សំខាន់គឺឲ្យព្រះកាយយាងចូលនៅក្នុងដួងចិត្តរបស់យើង"។ សេចក្តីនេះមានន័យថា ឲ្យដួងចិត្តរបស់យើងទៅជាព្រះវិហាររបស់ព្រះជាម្ចាស់ដ៏មានជីវិត។ ហេតុនេះហើយ ទោះបីនៅក្នុងព្រះវិហារមានទូរសម្រាប់ដាក់ព្រះកាយក្តីតែសំខាន់ឲ្យយើងដឹងថា នៅពេលណាយើងទទួលព្រះកាយព្រះគ្រីស្ត គឺខ្លួនរបស់យើង ដួងចិត្តរបស់យើងទៅជាព្រះវិហារដែលព្រះជាម្ចាស់យាងមកគង់នៅគឺគង់នៅតាមរយៈព្រះកាយព្រះគ្រីស្ត ព្រះអង្គមិនគង់នៅក្នុងព្រះវិហារដែលធ្វើអំពីថ្មទេ តែព្រះអង្គគង់នៅក្នុងព្រះវិហារដែលមានជីវិតវិញ។

សន្តីតេរេសា បានទទួលព្រះកាយព្រះគ្រីស្តលើកដំបូង នៅអាយុ៩ឆ្នាំ។ គាត់ចង់ទទួលព្រះកាយតាំងពីយូរហើយ គឺតាំងពីនៅតូច ពេលឃើញឪពុកម្តាយរបស់គាត់ បងស្រីរបស់គាត់ ឡើងទទួលព្រះកាយ។ នៅពេលគាត់ទទួលព្រះកាយលើកដំបូង គាត់យល់យ៉ាងច្បាស់អំពីអ្វីដែលកំពុងកើតឡើងនៅពេលនោះ គឺជាពេលដែលព្រះយេស៊ូយាងចូលនៅក្នុងខ្លួនរបស់គាត់។ សន្តីតេរេសាមានប្រសាសន៍ថា៖ "ពេលនោះ ហាក់បីដូចជាព្រះយេស៊ូបានថើបព្រលឹងរបស់នាងខ្ញុំ"។ ដូច្នេះ នៅពេលនោះគាត់មិនមែនទទួលនំប៉័ង មិនមែនទទួលសញ្ញាសម្គាល់មួយ មិនមែនទទួលនិមិត្តរូបមួយ តែទទួលព្រះយេស៊ូដែលយាងចូលក្នុងរាងកាយ និងព្រះអង្គថើបព្រលឹងរបស់គាត់យ៉ាងពិតប្រាកដទៀតផង។ សេចក្តីនេះ ណែនាំឲ្យយើងភ្ញាក់ស្មារតីថា គ្រប់ពេលដែលយើងទទួលព្រះកាយព្រះគ្រីស្ត នោះយើងត្រូវការរៀបចំចិត្តគំនិតឲ្យបានល្អ ឲ្យមានសេចក្តីស្រឡាញ់យ៉ាងពេញលក្ខណៈ ដើម្បីទទួលព្រះយេស៊ូនៅក្នុងរបៀបពិសេសបំផុត ដើម្បី

ស្វាគមន៍ព្រះអង្គយ៉ាងពិតប្រាកដមែន ដើម្បីព្រះអង្គយាងចូលនៅក្នុងខ្លួនរបស់យើង និងគង់នៅជាមួយយើង។

សន្តីតេរេសា មានប្រសាសន៍ដែរថា៖ "នៅពេលខ្ញុំទទួលព្រះកាយព្រះគ្រីស្ត ខ្ញុំរួមជាធ្លុងតែមួយជាមួយព្រះយេស៊ូ ពេលនោះមិនមែនខ្ញុំទេដែលនៅរស់ តែជាព្រះយេស៊ូដែលគង់នៅនៅក្នុងខ្ញុំ។ ខ្ញុំប្រៀបបីដូចជាទឹកមួយតំណក់ដែលធ្លាក់ទៅក្នុងសមុទ្រ ហើយទៅជាតែមួយជាមួយទឹកសមុទ្រ"។ នេះមានន័យថា សន្តីតេរេសាចូលនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ និងជាប់ជាមួយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់តែម្តង។ គាត់ជាទឹកមួយតំណក់ ដែលចូលនៅក្នុងមហាសមុទ្រនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ហេតុនេះហើយ ពេលយើងទទួលព្រះកាយព្រះគ្រីស្ត បើយើងគិតដូចនេះ យើងនិងទទួលព្រះកាយព្រះអង្គតាមរបៀបថ្មី យើងនឹងទទួលព្រះកាយព្រះអង្គដោយរៀបចំចិត្តគំនិតធ្វើជាធ្លុងតែមួយជាមួយព្រះអង្គ ដែលជាសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ។

សន្តីតេរេសា បន្ថែមទៀតថា៖ "ក្នុងអភិបូជា នៅពេលលោកបូជាចារ្យលើកព្រះកាយព្រះគ្រីស្តបង្ហាញអង្គប្រជុំ នៅពេលនោះ ខ្ញុំសម្លឹងឃើញព្រះភ័ក្ត្ររបស់ព្រះយេស៊ូភ្លឺយ៉ាងត្រចះត្រចង់តែម្តង"។ សេចក្តីនេះរំឭកយើងថា ក្នុងអភិបូជានៅពេលលោកឪពុកលើកព្រះកាយព្រះគ្រីស្តឡើង នោះយើងត្រូវយល់ថានេះជាព្រះភ័ក្ត្ររបស់ព្រះយេស៊ូពិតមែន ដែលកំពុងបំភ្លឺជីវិតរបស់យើង។ ពេលសន្តីតេរេសាចេញទៅទទួលព្រះកាយព្រះគ្រីស្ត គាត់យល់ឃើញថា គាត់កំពុងរស់នៅក្នុងសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ។ ដូច្នេះពេលយើងចេញទៅទទួលព្រះកាយព្រះគ្រីស្ត ចូរឲ្យយើងប្រមូលអារម្មណ៍ ព្រោះជាពេលដែលយើងត្រូវជួប និងចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូ ជាពេលវេលាដែលយើងទទួលសេចក្តីស្រឡាញ់ដ៏ពេញបរិបូរណ៍ពីព្រះអង្គ។ សន្តីតេរេសា បានមើលឃើញចំណិតនំប៉័ងតូចៗថា ជាព្រះកាយព្រះគ្រីស្ត។ សេចក្តីនេះរំឭកយើងថា ព្រះបិតាស្រឡាញ់យើង ព្រះអង្គជាព្រះដ៏ខ្ពង់ខ្ពស់បំផុត តែព្រះអង្គស្ម័គ្របន្ទាបព្រះកាយ

យាងចូលនៅក្នុងជីវិតរបស់យើង ដោយព្រះអង្គចាប់កំណើតជាមនុស្ស បូជាព្រះជន្មនៅលើឈើឆ្កាង ប្រទានព្រះកាយឲ្យយើងទទួលជារៀងរាល់អាទិត្យ និងរួមដំណើរជាមួយយើងជាមនុស្សបាប។

ព្រះជាម្ចាស់ស្រឡាញ់ចំពោះយើងម្នាក់ៗ ដោយព្រះអង្គសព្វព្រះហឫទ័យលើកលែងទោសឲ្យយើង នេះជាការអស្ចារ្យហួសពីការគិតរបស់យើង។ សន្តីតេរេសាមានបទពិសោធន៍អំពីការលើកលែងទោសនេះ ដោយគាត់មានប្រសាសន៍ថា៖ "ប្រសិនបើខ្ញុំបានធ្វើអំពើបាបធំជាងគេនៅលើផែនដីនេះ ខ្ញុំដឹងថា ព្រះជាម្ចាស់នឹងលើកលែងទោសឲ្យខ្ញុំ និងឲ្យខ្ញុំអាចធ្វើដំណើរតទៅទៀតបាន"។ សន្តីតេរេសាដឹងសេចក្តីនេះយ៉ាងច្បាស់ថា នៅក្នុងព្រះកាយព្រះគ្រីស្ត គឺយើងទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ យើងទៅជាអង្គតែមួយក្នុងព្រះគ្រីស្ត និងដោយយើងរួមជាមួយព្រះគ្រីស្ត នោះយើងជឿថា ព្រះជាម្ចាស់ដែលមានសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ ប្រោសប្រណីលើកលែងទោសឲ្យយើងជាអ្នកបាប។ បាបមិននាំឲ្យយើងអស់សង្ឃឹមទេ តែផ្ទុយទៅវិញ បាបប្រែទៅជាសេចក្តីសង្ឃឹមរបស់យើងថែមទៀត ដោយសារព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះអង្គយាងមកចាប់កំណើតជាមនុស្ស ដើម្បីភ្ជាប់យើងជាមួយនឹងព្រះអង្គរហូតដល់ព្រះអង្គសោយទិវង្គត។

ដោយសារបទពិសោធន៍នេះ ណែនាំឲ្យយើងមានជីវិតថ្មី មានកម្លាំងថ្មី ឲ្យយើងចង់ចែករំលែកជាមួយបងប្អូនឯទៀតៗ អំពីជីវិតដ៏អស្ចារ្យដែលយើងបានទទួលនេះ គឺខ្ញុំជាអ្នកបាប ខ្ញុំជាអ្នកតូចតាច ខ្ញុំជាមនុស្សទន់ខ្សោយ តែព្រះជាម្ចាស់យាងមកដើម្បីឲ្យខ្ញុំមានជីវិត ដើម្បីឲ្យខ្ញុំឈរឡើង ដើម្បីឲ្យខ្ញុំធ្វើដំណើររួមជាមួយព្រះយេស៊ូ ដែលស្រឡាញ់ខ្ញុំយ៉ាងខ្លាំង។ នេះជាអ្វីដែលយើងបានទទួលនៅពេលយើងទទួលព្រះកាយព្រះគ្រីស្ត គឺ "ព្រះយេស៊ូយាងមកថើបព្រលឹងរបស់ខ្ញុំនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ"។

យប់នេះ ពេលយើងទទួលព្រះកាយព្រះគ្រីស្ត ពេលយើងអធិដ្ឋានរួមជាមួយសន្តីតេរេសា ចូរយើងអនុវត្តបទពិសោធន៍ទាំងនេះ គឺព្រះយេស៊ូដែលយាងមក ដើម្បីថើបព្រលឹងខ្ញុំនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ ជីវិតខ្ញុំមានតម្លៃណាស់ ដ្បិតជាព្រះអំណោយទាន ជីវិតរបស់ខ្ញុំជាសេចក្តីស្រឡាញ់របស់ព្រះបិតា ទោះបីខ្ញុំជាអ្នកបាប ជាមនុស្សទន់ខ្សោយ ប៉ុន្តែព្រះជាម្ចាស់បានលើកលែងទោសឲ្យខ្ញុំគ្រប់ពេលវេលា។

ដូច្នេះ ខ្ញុំសូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ សូមឲ្យយើងម្នាក់ៗនៅក្នុងពេលអធិដ្ឋាន នៅក្នុងពេលថ្វាយអភិបូជា នៅក្នុងពេលស្តាប់ព្រះបន្ទូល នៅក្នុងពេលទទួលព្រះកាយព្រះគ្រីស្ត ឲ្យយើងមានបទពិសោធន៍ថា៖ "ព្រះយេស៊ូយាងមកថើបព្រលឹងរបស់ខ្ញុំ នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ"។ អាម៉ែន។











# សន្តិ តេរេសា និង មរណសាក្សី
# នៃសេចក្តីស្រឡាញ់ (តាំងគោក)

ថ្ងៃនេះ យើងនៅជិតសន្តិតេរេសា និងគ្រែរបស់លោកឆ្នាសាឡុស ណែនាំឲ្យយើងមានកម្លាំងថែមទៀត។ ខ្ញុំគិតថា ព្រឹកនេះពិសេសណាស់ សម្រាប់មរណសាក្សីនៅប្រទេសកម្ពុជា សម្រេចសន្តិតេរេសា និងសម្រាប់លោកអភិបាលអ៊ីវ៉ដែលប្រារព្ធឆ្នាំករុណា ទិគុណ។ នៅក្នុងព្រះសហគមន៍ទាំងមូលយើងជួបជុំគ្នានៅក្នុងអំណរសប្បាយដើម្បីកោតសរសើរព្រះជាម្ចាស់ ដែលមានព្រះជន្មរស់ឡើងវិញ។ យើងបានសួរខ្លួនឯងថា ថ្ងៃនេះ ទាំងមរណសាក្សី ទាំងសន្តិតេរេសា ទាំងលោកអភិបាលអ៊ីវ៉ និងយើងទាំងអស់គ្នាដែលនៅទីនេះ តើមានចំណុចអ្វីដែលណែនាំឲ្យយើងជួបជុំគ្នា?។ ខ្ញុំគិតថា ចម្លើយគឺចេញពីព្រះបន្ទូលរបស់ព្រះយេស៊ូអំបាញ់មិញ គឺសេចក្តីស្រឡាញ់ជាធម្មវិន័យថ្មី ដែលព្រះយេស៊ូបានប្រទានឲ្យយើង ហើយឲ្យយើងខិតខំអនុវត្តតាមធម៌វិន័យថ្មីនេះ គឺសូមឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះអង្គបានស្រឡាញ់យើងដែរ។ ប្រសិនបើយើងសួរលោកឆ្នាសាឡុស និងមរណសាក្សីនៅប្រទេសកម្ពុជាទាំងអស់ ថាតើមានអ្វីខ្លះដែលណែនាំឲ្យអស់លោក និងមរណសាក្សីមានជំនឿរឹងមាំ មានកម្លាំងតស៊ូទាំងមានចិត្តសង្ឃឹមនៅពេលរងទុក្ខលំបាកដ៏កំពូលនោះ? ខ្ញុំគិតថាមានចម្លើយតែមួយដែរ គឺសេចក្តីស្រឡាញ់ ជាសេចក្តីស្រឡាញ់ដែលព្រះយេស៊ូបានប្រទានឲ្យយើង ដែលព្រះអង្គបានបង្ហាញដ៏កំពូលនៅពេលព្រះអង្គបូជាព្រះជន្មនៅលើឈើឆ្កាង។

ស្រឡាញ់គឺប្រគល់អ្វីៗទាំងអស់ដែលខ្លួនមាន ដូចព្រះយេស៊ូដែលបានសោយព្រះទិវង្គតនៅលើឈើឆ្កាង។ លោកឆ្នាសាឡុស ដែលបានទទួលមរណ

ភាពនៅប៉ុន្មានម៉ែត្រពីទីនេះ និងមរណសាក្សីនៅប្រទេសកម្ពុជាឯទៀតៗ ដែលត្រូវបានគេសម្លាប់នៅប៉ុន្មានកន្លែងលើទឹកដីខ្មែរយើង គឺដោយសារតែមនុស្សជាច្រើន យើងវង្វេង ព្រឹកនេះពួកគាត់ប្រាប់ដល់យើងទាំងអស់គ្នាថា "សូមឲ្យមានចិត្តស្រឡាញ់ដូចព្រះយេស៊ូ"។ មរណសាក្សីទាំងអស់ មិនគ្រាន់តែនិយាយតែប៉ុណ្ណឹងទេ ប៉ុន្តែ ពួកគាត់បាន ផ្តល់សក្ខីភាពនៃសេចក្តីស្រឡាញ់នៅក្នុងជីវិតរបស់ពួកគាត់ផ្ទាល់យ៉ាងជាក់ស្តែងទៀតផង គឺរហូតដល់បូជាជីវិត។ យើងត្រូវតែស្តាប់ពួសម្លេងពីវាលស្រែដែលនៅទីនេះ យើងត្រូវតែស្តាប់ពួសម្លេងរបស់មរណសាក្សីដែលកំពុងស្រែករួមជាមួយព្រះយេស៊ូដែលសូមឲ្យយើងស្រឡាញ់ និងស្រឡាញ់ថែមទៀត។

លោកអភិបាលអ៊ីវជាគោរព! ខ្ញុំគិតថាជីវិតរបស់លោកអភិបាលបានបង្ហាញរឿងស្នេហារបស់លោកចំពោះប្រទេសកម្ពុជា ចំពោះព្រះសហគមន៍នៅប្រទេសកម្ពុជា និងចំពោះប្រជារាស្ត្រកម្ពុជាផ្ទាល់។ រយៈពេល៦០ឆ្នាំនៃរឿងស្នេហានេះមានដឹតដាមទៅដោយទុក្ខលំបាក និងសេចក្តីសុខក្សេមក្សាន្តនៅលាយឡំគ្នា ប៉ុន្តែ ទោះជាយ៉ាងណា ក៏សេចក្តីស្រឡាញ់បានផ្តល់បទពិសោធន៍ និងបានឈ្នះឧបសគ្គដូចលោកបានផ្តល់សក្ខីភាពរួចហើយ។ សូមអរគុណអំពីសក្ខីភាពរបស់លោកអភិបាលចំពោះព្រះសហគមន៍ អរគុណចំពោះស្នាមញញឹម និងសេចក្តីសង្ឃឹមរបស់លោកអភិបាល ដែលជាសក្ខីភាពមួយយ៉ាងពិសេស សម្រាប់មនុស្សជំនាន់ក្រោយ។ អរគុណលោកអភិបាល ដែលបានណែនាំឲ្យយើងខ្ញុំស្រឡាញ់ព្រះយេស៊ូ និងស្រឡាញ់ដូចព្រះយេស៊ូ។ ជីវិតរបស់លោកអភិបាលណែនាំឲ្យយើងយល់ថា ពិតមែននៅពេលយើងផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូនោះយើងពិតជានឹងទទួលអំណរសប្បាយលើសពីអ្វីៗទាំងអស់មកវិញដែរ។

សន្តីតេរេសា បានណែនាំជិត១០០ឆ្នាំហើយ។ យើងបានដើរជាមួយធាតុរបស់សន្តីនៅក្នុងភូមិភាគភ្នំពេញ មានមនុស្សរាប់ពាន់នាក់ទាំងក្មេង ទាំងចាស់

បានអំណរសប្បាយពេលបានជួបនឹងសន្តីតេរេសា។ យើងរំភើបចិត្ត ពេលឃើញក្មេងៗ អ្នកជំងឺ អ្នកពិការមកប៉ះសន្តីតេរេសាដើម្បីទទួលសេចក្តីសង្ឃឹមថែមទៀត។ ខ្ញុំសង្ឃឹមថា ដំណើររបស់សន្តីតេរេសានៅប្រទេសកម្ពុជា ណែនាំឲ្យយើងបានស្តាប់ឮសម្លេងរបស់គាត់ ដែលបានស្រែកអស់ពីដួងចិត្តថា៖ "នៅក្នុងបេះដូងព្រះសហគមន៍ជាមាតា ខ្ញុំនឹងជាសេចក្តីស្រឡាញ់" គឺជាសេចក្តីស្រឡាញ់សម្រាប់ព្រះយេស៊ូ ជាសេចក្តីស្រឡាញ់ជាមួយព្រះយេស៊ូ និងជាសេចក្តីស្រឡាញ់ក្នុងព្រះយេស៊ូ។

ខ្ញុំសូមសួរដល់បងប្អូន ដែលមកជួបជុំគ្នានៅថ្ងៃនេះថា៖ "ប្រសិនបើមានបងប្អូនឯទៀតមកគោះទ្វារព្រះសហគមន៍ តើយើងមានអ្វីខ្លះប្រគល់ឲ្យទៅគេ?។ សូមបងប្អូនស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូដែលបានឆ្លើយជំនួសយើង គឺថា៖ "សូមស្រឡាញ់ដូចខ្ញុំស្រឡាញ់អ្នក"។ ខ្ញុំសូមសួរមួយសំណួរទៀតទៅបងប្អូនថា៖ "តើព្រះសហគមន៍នៅប្រទេសកម្ពុជាយើង អាចស្រឡាញ់ដូចព្រះយេស៊ូបានស្រឡាញ់យើងបានយ៉ាងដូចម្តេច?"។ ព្រះយេស៊ូឆ្លើយដល់យើងម្តងទៀតថា៖ "សូមសម្លឹងមើលមកខ្ញុំនៅលើឈើឆ្កាង សូមមើលលោកឆ្មាសាឡាស និងសូមមើលមរណសាក្សីនៅប្រទេសកម្ពុជា សូមមើលសន្តីតេរេសា សូមមើលលោកអភិបាលអ៊ីវ អ្នកទាំងនេះជាសាក្សីនៃសេចក្តីស្រឡាញ់របស់ខ្ញុំ ហើយចូរចេញទៅផ្តល់សក្ខីភាពទៅ! ពេលនោះអ្នកអាចស្រឡាញ់ដូចខ្ញុំដែលបានស្រឡាញ់អ្នក។ សូមអ្នកមើលទឹកមុខរបស់ពួកគេ សូមមើលពីអំណរសប្បាយរបស់ពួកគេ ដែលផុសចេញពីដួងចិត្ត ពីជំនឿនៅពេលដែលគេឆ្លងកាត់ទុក្ខលំបាកយ៉ាងខ្លាំង"។

បងប្អូនជាទីស្រឡាញ់!

ទាំងលោកឆ្នាសាឡាស ទាំងសន្ដីតេរេសា ទាំងលោកអភិបាលអ៊ីវ ពួកគាត់បានឈ្នះឧបសគ្គដោយសារសេចក្ដីស្រឡាញ់ ហើយសក្ខីភាពរបស់ពួកគាត់បានណែនាំឲ្យយើងប្រែចិត្តគំនិត និងឲ្យយើងមានជីវិតថ្មី។ មរណសាក្សីរបស់យើង សន្ដៈសន្ដីបុគ្គលរបស់យើង និងបងប្អូនទាំងអស់ដែលបានធ្វើដំណើរមុនសម័យប៉ុលពតបានប្រាប់ដល់យើងថា៖ "ចូរស្រឡាញ់ និងចែកសេចក្ដីស្រឡាញ់នោះដល់មនុស្សទាំងអស់។ សូមឲ្យព្រះសហគមន៍នៅប្រទេសកម្ពុជាយើង បន្តរួមជាមួយព្រះយេស៊ូ ឲ្យយើងស្រឡាញ់កាន់តែច្រើនឡើងៗ។ យើងទាំងអស់គ្នា អាចកសាងពិភពលោកថ្មី សង្គមថ្មីបាន។ មានតែសេចក្ដីស្រឡាញ់ទេ ដែលឈ្នះគ្រប់អ្វីៗទាំងអស់។

អស់ពីដួងចិត្តរបស់យើង យើងសូមថ្លែងអំណរគុណដល់លោកឆ្នាសាឡាស ដល់សន្ដីតេរេសា ដល់មរណសាក្សីខ្មែរ ដល់លោកអភិបាលអ៊ីវ និងដល់បងប្អូនទាំងអស់ ដែលព្រមធ្វើជាសាក្សីរបស់ព្រះយេស៊ូក្នុងសង្គម។ ខ្ញុំសូមបងប្អូនទាំងអស់និយាយរួមជាមួយសន្ដីតេរេសាថា៖ "នៅក្នុងបេះដូងនៃព្រះសហគមន៍ជាមាតា ខ្ញុំនឹងជាសេចក្ដីស្រឡាញ់" យើងនិយាយហើយយើងខិតខំអនុវត្តតាមឲ្យបាន។

ជ័យយោ ព្រះសហគមន៍នៅប្រទេសកម្ពុជា! ជ័យយោ សន្ដីតេរេសា! ជ័យយោ ព្រះយេស៊ូ!។ អាម៉ែន។










# យើងទាំងអស់ សូមអរគុណ

## សន្តី តេរេសា (អារាមកាមែល)

ថ្ងៃនេះយើងមានបងស្រី និងបងប្អូនយ៉ាងច្រើនចូលរួម ដើម្បីលាសន្តីតេរេសា។ ដូច្នេះពេលនេះ ខ្ញុំសូមសរុបអំពីដំណើររបស់សន្តីតេរេសា ដោយបង្ហាញអំពីសកម្មភាព និងអ្វីដែលយើងបានទទួល។ ពេលសន្តីតេរេសាមកដល់ភ្លាម យើងបាននាំទៅអរិយក្សេត្រ ដែលជាកន្លែងមួយយ៉ាងពិសេស មានព្រះនាងម៉ារីនៃទន្លេមេគង្គនៅទីនោះ។ យើងបាននាំ សន្តីតេរេសា ឡើងទៅលើភ្នំព្រះនាងម៉ារីនៃទន្លេមេគង្គ ជាឱកាសសម្រាប់ឲ្យគ្រីស្តបរិស័ទយើងរិះគិតអំពីសន្តីតេរេសានិងព្រះនាងម៉ារី ជាពិសេសគិតអំពីរបៀបដែលសន្តីតេរេសាបានយកព្រះនាងម៉ារីទុកជាម្តាយ នៅពេលម្តាយបង្កើតរបស់គាត់ទទួលមរណភាព និងនៅពេលបងស្រីរបស់គាត់ចូលអារាមកាមែល ដែលពេលនោះ គាត់មានអារម្មណ៍ឯកាខ្លាំងណាស់ តែគាត់យល់ឃើញថា ត្រូវយកព្រះនាងម៉ារីទុកជាម្តាយ ទុកជាទីពឹងរបស់គាត់។ មុនទទួលមរណភាព សន្តីតេរេសាបានសរសេរកំណាព្យមួយបង្ហាញអំពីរបៀបដែលគាត់ស្រឡាញ់ព្រះនាងម៉ារី។

យើងបានចាប់ផ្តើមធ្វើដំណើរជាមួយសន្តីតេរេសា រួមជាមួយព្រះនាងម៉ារី និងបន្ទាប់មក យើងនាំសន្តីតេរេសាទៅព្រះសហគមន៍ផ្សារតូច និងបឹងទំពុន។ រយៈពេលពីរថ្ងៃនៅទីនោះ ជាពេលមួយពិសេស ដោយយើងបានអធិដ្ឋានអំពីការត្រាស់ហៅ។ កន្លងមកសន្តីតេរេសា បានជួយដល់និស្សិតទេវវិទ្យាល័យជាច្រើន ឲ្យរកឃើញផ្លូវសម្រាប់ជីវិតរបស់គេ ដូច្នេះពេលនេះ ក៏ជាឱកាសមួយយ៉ាងអស្ចារ្យសម្រាប់ការត្រាស់ហៅដែរ។ ឆ្នាំនេះយើងមានអ្នកចូលរួមអធិដ្ឋានជាមួយ

សន្តីតេរេសាសម្រាប់ការត្រាស់ហៅ ជាង២០០នាក់ ដែលមកពីក្រុមអេម៉ាណូអែល មីកាអែល សាមូ៉អែល ដែលជួយឲ្យគេភ្ញាក់ស្មារតីកាន់តែច្រើនទៅៗ។

នៅផ្សារតូច យើងបានតម្កល់កោដ្ឋសន្តីតេរេសា ក្បែរនឹងធាតុឪពុកម្ដាយរបស់គាត់ នេះជាពេលមួយ ជួយឲ្យយើងរិះគិតរកអត្ថន័យនៃក្រុមគ្រួសារ។ ក្រោយមកយើងបាននាំសន្តីតេរេសាទៅមណ្ឌលសកម្មភាពមេគង្គ ជាឱកាសមួយឲ្យបងប្អូនគ្រីស្តបរិស័ទយើងនៅទីនោះស្វាគមន៍គាត់យ៉ាងរីករាយ។ នៅចំប៉ា បងប្អូនយើងនិយាយថា គេទន្ទឹងសន្តីតេរេសាជិត១០០ឆ្នាំហើយ គឺតាំងពីដូនតាគេមកម្ល៉េះ នេះបង្ហាញថា គេចង់ជួបសន្តីតេរេសាខ្លាំងណាស់។ នៅទីនោះ យើងបានរិះគិតអំពីសន្តីតេរេសានិងព្រះយេស៊ូ ថាតើសន្តីតេរេសាមានទំនាក់ទំនងជាមួយព្រះយេស៊ូយ៉ាងដូចម្ដេច?។ ព្រះយេស៊ូ ជាផ្លូវមួយយ៉ាងពិសេស នាំយើងទាំងអស់គ្នាឲ្យទៅជាសន្តៈសន្តី នៅក្នុងសួនច្បាររបស់ព្រះជាម្ចាស់។ យើងទាំងអស់គ្នា ស្ថិតនៅក្នុងព្រះហស្តរបស់ព្រះយេស៊ូ យើងដឹងថាព្រះយេស៊ូជួយយើងទោះបីយើងជាមនុស្សបាប។

បន្ទាប់មក យើងបន្តទៅមាត់សមុទ្រ នៅព្រះសហគមន៍ក្រុងព្រះសីហនុ។ នៅទីនោះ យើងបានបន្តរិះគិតអំពីការអធិដ្ឋាន។ សន្តីតេរេសាបានណែនាំឲ្យយើងចេះអធិដ្ឋាន ដើម្បីឲ្យជីវិតរបស់យើងជាគ្រីស្តបរិស័ទរីកចម្រើននៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ការអធិដ្ឋាន ជាពេលមួយដើម្បីអង្គុយជាមួយព្រះយេស៊ូ ទាំងពោលពាក្យដែលមាននៅក្នុងចិត្តរបស់យើង ដោយដឹងថាពេលណាយើងអរព្រះគុណព្រះជាម្ចាស់ម្ដង នោះព្រះអង្គនឹងប្រទានពរឲ្យយើងដប់ដងវិញ។ ក្រោយមកយើងបន្តទៅកំពត នៅទីនោះ មានបងប្អូនជាច្រើនមកស្វាគមន៍សន្តីតេរេសាទាំងមានអំណរ។ ពេលយើងទៅដល់ជុំគីរីមានក្មេងៗកាយរិទ្ធិ៥០០នាក់ ឈរចាំទទួលសន្តីតេរេសាតាមផ្លូវចូល ប្រហែលមួយគីឡូម៉ែត្រ។ ក្មេងៗទាំងនោះ សុទ្ធតែជាកូនពុទ្ធបរិស័ទទាំងអស់ ក្រោយមក យើងឲ្យពួកគេនៅជុំវិញសន្តីតេរេសាទាំងពោលថា៖ "ឱសន្តី តេរេសា! សូមជួយឲ្យ

ខ្ញុំក្លាយជាកូនល្អ ឲ្យខ្ញុំចេះគោរពឪពុកម្តាយផង!"។ ក្រោយមកគ្រីស្តបរិស័ទយើង រួមគ្នាអធិដ្ឋាននៅឯវាលស្រែ ហើយនេះជាលើកទីមួយ ដែលសន្តីតេរេសាបានទៅដល់កន្លែងដែលមានដើមត្នោត ដើមដូងនៅជុំវិញ។ នៅទីនោះ យើងបន្តរិះគិតអំពីសន្តីតេរេសា និងព្រះកាយព្រះគ្រីស្ត ដើម្បីឲ្យគ្រីស្តបរិស័ទយល់ថា នៅពេលគេទទួលព្រះកាយព្រះគ្រីស្ត គឺព្រះយេស៊ូយាងចូលក្នុងខ្លួនគេ និងយាងមកសង្គ្រោះគេយ៉ាងពិតប្រាកដមែន។ សន្តីតេរេសាទទួលព្រះកាយព្រះគ្រីស្តលើកទីមួយ នៅអាយុ៩ឆ្នាំ ហើយគាត់មានប្រសាសន៍ថា៖ "...ពេលនោះព្រះយេស៊ូថើបព្រលឹងរបស់នាងខ្ញុំ"។

ក្រោយមកយើងទៅតាកែវ យើងទៅសាលាមត្តេយ្យសន្តីតេរេសា នៅទីនោះក្មេងៗទាំងអស់ដែលមកទទួល បានមកប៉ះកោដ្ឋសន្តីតេរេសា គេសប្បាយចិត្ត គេមានភាពស្និទ្ធស្នាល ដ្បិតគេបានស្គាល់សន្តីតេរេសារួចទៅហើយ តាមការអានសៀវភៅរបស់សន្តីតេរេសា និងទាំងបានឃើញរូបភាពផង។ នៅសាលាសន្តៈហ្វ្រង់ស្វ័រឯណោះវិញ បងប្អូនយើងពីគ្រប់ព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពតាកែវ មកស្វាគមន៍សន្តីតេរេសាដោយនៅជាមួយគ្នារហូតដល់យប់ ហើយយើងបន្តអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ។ ខ្ញុំរំភើបចិត្ត ដោយសារនៅទីនោះមានគ្រីស្តបរិស័ទបានសរសេរលិខិតមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់ ចំពោះវត្តមានរបស់សន្តីតេរេសាដែលបានទៅដល់ទីនោះ និងជាលើកទីមួយដែលបងប្អូនបានស្គាល់ និងឃើញ និងទទួលបទពិសោធន៍ថ្មី ណែនាំឲ្យទាំងអស់គ្នាមានពន្លឺថ្មីនៅក្នុងជីវិតរបស់គេ។

បន្ទាប់មក យើងចេញដំណើរមកសាលាដុនបូស្កូ នៅទីនោះមានសិស្សរាប់ពាន់នាក់មកស្វាគមន៍សន្តីតេរេសា មានសិស្សជាច្រើនបានសរសេរពាក្យអធិដ្ឋានដោយអស់ពីចិត្ត តាមរយៈសន្តីតេរេសា ទោះបីគេមិនមែនជាគ្រីស្តបរិស័ទក៏ដោយ។ ក្រោយមក យើងបានទៅកន្លែងបងស្រីមេត្តាករុណានៅចោមចៅ ដែលផ្តល់ឱកាសពិសេសដល់បងប្អូនអ្នកជំងឺ។ យើងជួបជុំគ្នានៅក្នុង

ព្រះវិហាររបស់បងស្រី ដែលមានធាតុរបស់អ្នកម្ដាយតេរេសា។ ក្នុងពិធីនោះ មានម្នាក់បានអានអត្ថបទមួយរបស់អ្នកម្ដាយតេរេសា នាំឲ្យយើងយល់ថា សន្ដី តេរេសា និងអ្នកម្ដាយតេរេសាមានចិត្តតែមួយ។ យើងក៏បានផ្ដល់ឱកាសសម្រាប់ ក្មេងៗដែលមានជំងឺ មកអធិដ្ឋានទាំងទុកចិត្តនៅជុំវិញកោដ្ឋសន្ដីតេរេសា ដើម្បី សុំឲ្យពួកគេបានជាពីជំងឺផ្សេងៗ។

ក្រោយមក មានការជួបជុំដ៏កំពូលនៅតាំងគោក។ មានអ្នកចូលរួមជាង ៣០០០នាក់ គេមកដើម្បីអធិដ្ឋានសម្រាប់លោកអភិបាលអ៊ីវ និងដើម្បីស្វាគមន៍ សន្ដីតេរេសាដែលបានតម្កល់នៅលើគ្រែរបស់លោកឆ្មាសាទ្បាស។ នៅពេល លោកអភិបាល លោកបូជាចារ្យ និងបងប្អូនទាំងអស់លុតជង្គង់ដើម្បីទូលអង្វរ សន្ដះសន្ដីបុគ្គល ពេលនោះណែនាំឲ្យយើងយល់ថា ស្ថានបរមសុខនៅមិនឆ្ងាយ ពីគ្នាទេ។ ក្រោយមកសន្ដីតេរេសា បានបន្តដំណើរទៅកំពង់ចាម បាត់ដំបង ហើយបានទៅភូមិចំណោម ដែលមានព្រះសហគមន៍មួយឈ្មោះថា "សន្ដីតេរេសា នៃព្រះកុមារយេស៊ូ"។ នៅទីនោះយើងអធិដ្ឋានរួមជាមួយគ្រីស្ដបរិស័ទដែលបាន ទន្ទឹងរង់ចាំសន្ដីតេរេសាតាំងពីយូរមកហើយ។

ក្រោយមក សន្ដីតេរេសាបានមកភ្នំពេញវិញ យើងទៅស្វាយប៉ាកបន្ទិច និង ក្រោយមកបន្តដំណើរទៅជ្រៃធំ។ នៅទីនោះ ក្រុមកុមារតេរេសាបានមកទទួល ស្វាគមន៍ និងមានសម្ដែងរឿងសន្ដីតេរេសាទៀតផង។ យើងអធិដ្ឋានរហូតដល់ ម៉ោង១២យប់។ ពេលលើកកោដ្ឋសន្ដីតេរេសា ដាក់ក្នុងឡានត្រឡប់មកវិញ ពេលនោះមានបងប្អូនជាច្រើនបានយំយ៉ាងខ្លាំង ដូចជាត្រូវបែកពីមិត្តសម្លាញ់ របស់គេយ៉ាងដូច្នោះដែរ។ ពេញមួយយប់ សន្ដីតេរេសាបានសម្រាកនៅក្នុងផ្ទះ របស់គាត់យ៉ាងស្ងៀមស្ងាត់ ដោយសារ៣អាទិត្យកន្លងមក មិនបានស្ងៀមស្ងាត់ទេ។

ព្រឹត្តិការណ៍ទាំងនេះណែនាំឲ្យយើងបន្តទៅមុខទៀតរួមជាមួយសន្ដីតេរេសា រួមជាមួយព្រះនាងម៉ារី និងជាពិសេសក្នុងឱកាសបុណ្យព្រះវិញ្ញាណយាងមក

នេះ ដើម្បីឲ្យជីវិតរបស់យើងជាធ្លុងតែមួយជាមួយព្រះយេស៊ូ តាមគំរូរបស់សន្ដិតេរេសា ដើម្បីបន្ដកសាងព្រះសហគមន៍របស់យើង។

ចូរយើងបន្ដអរព្រះគុណព្រះជាម្ចាស់ នៅក្នុងអភិបូជានេះ អរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍យើង អរព្រះគុណព្រះជាម្ចាស់សម្រាប់ក្រុមគ្រួសារបងស្រី បងប្រុស ដើម្បីឲ្យយើងរួមជាមួយគ្នាទៅជាធ្លុងតែមួយនៅក្នុងអង្គព្រះយេស៊ូគ្រីស្ដ។ អាម៉ែន។









# អដ្ឋិធាតុសន្តីថេរេសា មកដល់ពោធិ៍ចិនតុង
# និងមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញខាងត្បូង























# អដ្ឋិធាតុសន្តីថេរេសា មកដល់មណ្ឌលសកម្មភាព
# ព្រះសហគមន៍កាតូលិក តំបន់ទន្លេមេគង្គ











# អដ្ឋិធាតុសន្តីថេរេសា មកដល់មណ្ឌលសកម្មភាព
# ព្រះសហគមន៍កាតូលិក ខេត្តព្រះសីហនុ

















# អដ្ឋិធាតុសន្តីថេរេសា មកដល់មណ្ឌលសកម្មភាព ព្រះសហគមន៍កាតូលិក ខេត្តកំពត















# អដ្ឋិធាតុសន្តីថេរេសា មកដល់សាលាដុនបូស្កូទឹកថ្លា និងភូមិគ្រឹះសន្តិភាព នៃបងស្រីមេត្តាករុណា


















# អដ្ឋិធាតុសន្តីថេរេសា មកដល់មណ្ឌលសកម្មភាព
# ព្រះសហគមន៍កាតូលិក ខេត្តតាកែវ





















# អដ្ឋិធាតុសន្តីថេរេសា មកដល់មណ្ឌលសកម្មភាព ព្រះសហគមន៍កាតូលិក តំបន់ទន្លេបាសាក់












# អដ្ឋិធាតុសន្តីថេរេសា មកដល់មណ្ឌលសកម្មភាព ព្រះសហគមន៍កាតូលិក ភ្នំពេញខាងជើង





















# អដ្ឋិធាតុសន្ដីថេរេសា
# មកដល់ព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម



















# អដ្ឋិធាតុសន្តីថេរេសា
# មកដល់ព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង















# អដ្ឋិធាតុសន្តីថេរេសា
# មកដល់អារាមដូនជីសម្រាត់ ភ្នំពេញ





















# អដ្ឋិធាតុសន្តីថេរេសា
# មកដល់ដីមរណសាក្សី នៅតាំងគោក














# អដ្ឋិធាតុសន្តីថេរសោ
# ត្រឡប់ទៅប្រទេសបារាំងវិញ









# ចំណាប់អារម្មណ៍របស់គ្រីស្តបរិស័ទ
# ចំពោះការទទួលអដ្ឋិធាតុសន្តីថេរេសា



## លោកអភិបាល គីកេ ហ្វីការេដូ

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង

ការមកដល់របស់ធាតុសន្តី ថេរេសា គឺមានប្រយោជន៍ច្រើនមិនត្រឹមតែសម្រាប់ការត្រាស់ហៅ តែក៏សម្រាប់គ្រីស្តបរិស័ទទាំងអស់ដែរ។ ពេលណាយើងគិតទៅដល់សន្តីថេរេសា គឺហាក់ដូចជាគាត់នៅជិតយើង ហើយគំរូរបស់គាត់ធ្វើឲ្យយើងយល់ពីជីវិតដ៏អស្ចារ្យ ដែលជាមនុស្សសាមញ្ញ អត់មានអ្វីដែលពិសេសទេ។ ប៉ុន្តែជីវិតរបស់គាត់ គឺរស់នៅជាប់ជាមួយព្រះជាម្ចាស់។

ខ្ញុំឃើញ ពេលធាតុមកដល់ បងប្អូនមានអារម្មណ៍ចង់ដឹង ចង់ស្តាប់ និងចង់ស្គាល់ច្រើនដូចជាបង្កើតបរិយាកាសពិសេសម្យ៉ាង។ កម្មវិធីនេះ គឺឲ្យយើងនៅជិតស្និទ្ធជាមួយសន្តីម្នាក់។ កាលណាឃើញធាតុ គឺដូចជាឃើញសន្តីថេរេសាមកសួរសុខទុក្ខយើង ទោះបីជីវិតរបស់គាត់រស់នៅជាង១៥០ឆ្នាំហើយក៏ដោយ។ គំរូនៃការអធិដ្ឋានរបស់គាត់សាមញ្ញជាមួយព្រះជាម្ចាស់ គឺដាក់ខ្លួនជាអ្នកតូចតាចក្នុងជីវិតរស់នៅប្រចាំថ្ងៃ នេះមានសារៈសំខាន់ណាស់សម្រាប់ព្រះជាម្ចាស់។ សម្រាប់យុវជន-នារី ត្រូវតែចាប់អារម្មណ៍ឲ្យជីវិតរបស់ខ្លួនរស់នៅយ៉ាងជិតស្និទ្ធជាមួយសន្តបុគ្គលដែលនាំឲ្យខ្លួនជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ផងដែរ។

ខ្ញុំសូមអរគុណលោកអភិបាលអូលីវីយេ ដែលបានអញ្ជើញធាតុសន្តីថេរេសាមកស្រុកខ្មែរ ដែលធ្វើឲ្យយើងជិតស្និទ្ធជាមួយនឹងសន្តីថេរេសាថែមទៀត។



## លោកបូជាចារ្យ ពេត្រូ ភូមេស៍

ព្រះសហគមន៍បំណោម ខេត្តបន្ទាយមានជ័យ

ខ្ញុំឃើញថា បងប្អូនមានអារម្មណ៍រំភើប សប្បាយចិត្តខ្លាំងណាស់។ យើងបានដង្ហែធាតុសន្តិថេរេសា ហើយចូលព្រះវិហារអធិដ្ឋាន និងថ្វាយអភិបូជា។ សម្រាប់យើងសំខាន់ណាស់ ព្រោះសន្តិថេរេសាជាឧបការីរបស់ព្រះសហគមន៍នៅទីនេះ។ ការមកដល់របស់ធាតុសន្តិថេរេសា ជំរុញឲ្យបងប្អូនចូលរួមអធិដ្ឋាន ភ្ជាក់ស្មារតី និងមានជំនឿ។ ចំពោះខ្ញុំ ខ្ញុំមានអារម្មណ៍ថា នេះជាកាដូមួយពិសេស ដែលព្រះជាម្ចាស់ប្រទានឲ្យយើង គឺសន្តីថេរេសាដែលឲ្យយើងចេះស្រឡាញ់ព្រះជាម្ចាស់ និងព្រះសហគមន៍ តាមរបៀបសាមញ្ញ ដោយធ្វើកិច្ចការតូចតាច ដោយសេចក្តីស្រឡាញ់ នៅពេលយើងធ្វើកិច្ចការងារ និងពេលយើងជួបបងប្អូនឯទៀតៗ។



## បងស្រី ម៉ិន ថារីន

ក្រុមគ្រួសារបងស្រីស្រឡាញ់ព្រះឈើឆ្កាង

ខ្ញុំពិតជាមានអារម្មណ៍រំភើបមែនទែន ដោយសារជាលើកទីមួយដែលខ្ញុំបានឃើញហេតុការណ៍នេះ ហើយណាមួយព្រះសហគមន៍ពិតជាមានការយកចិត្តទុកដាក់ជាមួយអ្នកបួសខ្លាំងមែនទែន ដោយព្យាយាមស្វះស្វែងនាំធាតុសន្តិថេរេសាពីបារាំងមកដល់ស្រុកខ្មែរសម្រាប់បងប្អូនខ្មែរបានឃើញ និងរំឭកដល់សេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះយេស៊ូដែលជាគំរូសម្រាប់យើងទាំងអស់គ្នា។ ទោះបីជាបងស្រីថេរេសាបានទទួលមរណភាពជាយូរមកហើយក៏ដោយ តែខ្ញុំនៅមានអារម្មណ៍ថាបងស្រីកំពុងរួមជាមួយយើងទាំងអស់គ្នា។

ពេលខ្ញុំបានទៅជិតធាតុសន្តីថេរេសាភ្លាម ខ្ញុំពិតជាមានអារម្មណ៍រំភើប និងមានកម្លាំងក្នុងចិត្តដើម្បីអធិដ្ឋាន សូមឲ្យបងស្រីជួយទូលអង្វរព្រះជាម្ចាស់សម្រាប់បងប្អូនជាគ្រីស្តបរិស័ទដែលរស់នៅលើផែនដីនេះ។ ធាតុបងស្រីថេរេសាពិតជាបានជួយខាងផ្លូវវិញ្ញាណខ្ញុំច្រើនណាស់ គឺខ្ញុំមានអារម្មណ៍កក់ក្តៅ និងមានជំនឿកាន់តែរឹងមាំថែមទៀត ពេលដែលឃើញធាតុរបស់គាត់ គឺមានកម្លាំងដើម្បីបម្រើព្រះសហគមន៍តទៅមុខទៀត ទោះបីជាមានឧបសគ្គក៏ដោយ។



## អ្នកស្រី ប៊ុណ្ណារ៉ាត

គ្រីស្តបរិស័ទនៅព្រះសហគមន៍កំពង់ចាមក្រុង

ពេលដែលខ្ញុំបានឃើញធាតុសន្តីថេរេសាមកដល់ប្រទេសកម្ពុជាយើង ខ្ញុំមានអារម្មណ៍ប្លែក ហើយយល់ថា ជីវិតខាងផ្លូវវិញ្ញាណពិតជាមានពិតមែនដោយសារពីមុនខ្ញុំអត់សូវមានជំនឿខាងផ្លូវវិញ្ញាណទេ អ្វីដែលខ្ញុំមានជំនឿ គឺសេចក្តីស្រឡាញ់។ ពេលដែលព្រះសហគមន៍ រំឭកដល់ជីវិតរបស់សន្តីថេរេសា គឺបងស្រីបានលះបង់ធំធេង និងមានសេចក្តីស្រឡាញ់ណាស់ចំពោះព្រះយេស៊ូ ដែលធ្វើខ្ញុំគិតថា ខ្លួនខ្ញុំបានលះបង់តិចតួចណាស់សម្រាប់ព្រះយេស៊ូ។ សន្តីថេរេសាបានធ្វើឲ្យខ្ញុំមានចិត្តស្ងប់ និងរំភើបចំពោះកូនស្រីរបស់ខ្ញុំដែលបានចូលបួស។ ដោយសារពីមុនខ្ញុំមានអារម្មណ៍ពិបាកចិត្តចំពោះរឿងនេះដោយសារយល់ថា មិនដែលមានម្តាយណាដែលមានកូនស្រីតែម្នាក់បែរជាលះបង់ឲ្យកូនស្រីទៅបួសនោះទេ។ ប៉ុន្តែឥឡូវខ្ញុំយល់ថា ខ្ញុំបានផ្តល់សេចក្តីស្រឡាញ់របស់ខ្ញុំដល់ព្រះយេស៊ូដែលយល់ព្រមឲ្យកូនស្រីចូលបួស។




## បងប្រុស ផាន បូរី

និស្សិតទេវវិទ្យាល័យ

វត្តមានរបស់សន្តីថេរេសាសំខាន់ណាស់សម្រាប់គ្រីស្តបរិស័ទ។ ខ្ញុំឃើញថា ធាតុសន្តីថេរេសាបានជួយពង្រឹងជំនឿគ្រីស្តបរិស័ទយ៉ាងច្រើន គឺធ្វើឲ្យគ្រីស្តបរិស័ទភ្ញាក់ស្មារតីអំពីគំរូនៃទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់។ យើងបានអានសៀវភៅ យើងឃើញធាតុរបស់គាត់ផ្ទាល់ គ្រីស្តបរិស័ទប៉ះ និងអធិដ្ឋានសុំអ្វីមួយពីសន្តីតេរេសា។ ពេលនៅរស់សន្តីថេរេសាប្រាថ្នាចង់ក្លាយជាបេសកជនដែលប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ ដល់មនុស្សទាំងអស់។ ពេលខ្ញុំឮចំណុចនេះ នាំឲ្យចិត្តខ្ញុំរំភើប និងចង់ចែកជំនឿដូចគាត់ដែរ។ ពេលខ្ញុំទៅតាមព្រះសហគមន៍នីមួយៗ ខ្ញុំតែងគិតពីសន្តីថេរេសាដែលចង់ប្រកាសដំណឹងល្អនេះ ហើយវាបានជួយលើកទឹកចិត្តខ្ញុំ ដើម្បីបន្តដំណើរទៅមុខចំពោះការថ្វាយខ្លួនទៅព្រះជាម្ចាស់ និងការប្រកាសដំណឹងល្អ។ របៀបដែលសន្តីថេរេសាមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ គឺល្អណាស់សម្រាប់ យើងជាបព្វជិត បព្វជិតា គ្រីស្តបរិស័ទ គួរយកគំរូតាមគាត់ ដែលនាំឲ្យជីវិតខាងវិញ្ញាណរស់នៅជិតស្និទ្ធជាមួយព្រះជាម្ចាស់។



## បងប្រុស សុខណា

និស្សិតទេវវិទ្យាល័យ

ខ្ញុំបានអានប្រវត្តិសន្តីថេរេសា ៤-៥ឆ្នាំមុននេះ។ ខ្ញុំមានចិត្តរំភើបណាស់ពេលធាតុរបស់គាត់មកដល់។ យើងគួរអរគុណដល់ព្រះជាម្ចាស់ និងព្រះសហគមន៍ដែលបានឲ្យមានវត្តមានសន្តីថេរេសានៅស្រុកខ្មែរ។ ជីវិតរបស់គាត់តូចតាច តែមានសេចក្តីក្លាហានណាស់។ ជីវិតដែលរស់នៅក្នុងអារាមតែ

មួយកន្លែង បើយើងគិតទៅវាពិបាកណាស់។ ប៉ុន្តែគាត់អាចរស់នៅបាន។ គាត់ក្លាហាននៅពេលជួបឧបសគ្គ។ នៅពេលគាត់សុំបួស ដែលមានលោកអភិបាលជំទាស់គាត់ និងគ្រួសារហ៊ានស្នើសុំទៅដល់សម្តេចប៉ាបទៀត។ មួយវិញទៀតខ្ញុំឃើញថា ទំនាក់ទំនងនៅក្នុងគ្រួសាររបស់គាត់ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ និងជាការត្រាស់ហៅពិសេសមួយ។ ពួកគាត់លើកទឹកចិត្តគ្នាទៅវិញទៅមកនៅពេលជួបឧបសគ្គ ហើយបងប្អូនស្រីទាំង ៥នាក់បានចូលបួសក្នុងអារាមទាំងអស់។

ចំណុចទាំងនេះ បានលើកទឹកចិត្តខ្ញុំ ព្រោះភាពក្លាហានរបស់គាត់ ការជឿទុកចិត្តរបស់គាត់លើព្រះយេស៊ូ និងការគាំទ្រពីគ្រួសារ នាំឲ្យគាត់អាចទៅមុខបាន។ នេះជាអ្វីដែលខ្ញុំសប្បាយចិត្ត ព្រោះដូចជាជីវិតរបស់ខ្ញុំដែលមានគ្រួសារជួយគាំទ្រ ដែលនាំឲ្យជីវិតខាងវិញ្ញាណរបស់ខ្ញុំអាចទៅមុខបាន។

ធាតុសន្តីថេរេសាបានឲ្យជីវិតរបស់ខ្ញុំឥឡូវនេះ ភ្ជាប់ជាមួយព្រះជាម្ចាស់នាំឲ្យខ្ញុំច្បាស់ពីគោលដៅ និងមិនភ័យខ្លាចទោះបីជាមានបញ្ហា ខ្ញុំអាចបន្តទៅមុខបានដោយមានព្រះយេស៊ូ និងព្រះសហគមន៍។



## លោក ភាន់ ម៉ុយ

គណៈកម្មាការព្រះគម្ពីរកាតូលិកកម្ពុជា

ដំបូងខ្ញុំមានការចម្លែកក្នុងចិត្តបន្តិចនៅពេលខ្ញុំឃើញធាតុរបស់សន្តីថេរេសា។ ចម្លែក! ពីព្រោះថា ធាតុរបស់សន្តីថេរេសា បានរំឭកឲ្យខ្ញុំនឹកឃើញដល់អនុស្សាវរីយ៍កាលខ្ញុំកំព្រាម្តាយតាំងពីក្មេង។ ពេលនោះ ខ្ញុំចូលចិត្តសញ្ជប់សញ្ជឹងនឹករឭកនៅខាងមុខធាតុម្តាយរបស់ខ្ញុំ តែក្រោយមកនៅពេលឪពុករបស់ខ្ញុំទទួលមរណភាព គេបានយកធាតុនោះទៅ បញ្ចុះក្នុងផ្នូររួមជាមួយ

គ្នាក្នុងពេលបូជាសព។ តាំងពីពេលនោះមក ជីវិតរបស់ខ្ញុំ មានតែភាពវិលវល់ តប់ប្រមល់ លែងរវីរវល់អំពីធាតុតទៅទៀត។ មិនតែប៉ុណ្ណោះ ធាតុរបស់សន្តីថេរេសា បានដាស់សតិរបស់ខ្ញុំឲ្យភ្ញាក់ស្មារតី យកចិត្តទុកដាក់រស់នៅតាមគំរូរបស់គាត់ ដោយមានជំនឿមាំមួនលើព្រះជាម្ចាស់ យកចិត្តទុកដាក់អធិដ្ឋាន រិះគិតអំពីជីវិតខាងផ្លូវវិញ្ញាណ និងចេះគោរពស្រឡាញ់ចំពោះអ្នកដទៃ។ ចំណុចទាំងនេះហើយដែលជាស្នូលធ្វើឲ្យជីវិតរបស់ខ្ញុំល្អប្រសើរ លែងតូចចិត្ត នឹងវាសនា លែងមានអារម្មណ៍ឯកោដូចកាលពីមុន ហើយនាំមកនូវសេចក្តីសង្ឃឹម និងទីពឹងថ្មី។



**បងស្រី ព្រំ ផល្លា**

ក្រុមបុត្រីបម្រើភូមិ

ខ្ញុំចាប់អារម្មណ៍ពីជីវិតរបស់សន្តីថេរេសាខ្លាំងជាងគេ គឺត្រង់ផ្លូវវិញ្ញាណរបស់គាត់ ដែលធ្វើឲ្យយើងមើលឃើញពីលក្ខណៈតូចតាច ដោយធ្វើកិច្ចការងារដែលមានប្រយោជន៍សម្រាប់ព្រះជាម្ចាស់។ ជីវិតផ្លូវវិញ្ញាណ សេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងកិច្ចការរបស់សន្តីថេរេសា នាំឲ្យខ្ញុំទទួលកម្លាំងខាងវិញ្ញាណយ៉ាងច្រើន ដើម្បីបន្តកិច្ចការបម្រើនៅក្នុងសង្គម និងក្នុងព្រះសហគមន៍កាតូលិក។



បោះពុម្ពនៅភ្នំពេញ ឆ្នាំ ២០១៣
©មណ្ឌលអប់រំជំនឿកាតូលិកកម្ពុជា (CCCC)
ផ្ទះលេខ ៥៧ ផ្លូវលេខ ១០១ សង្កាត់បឹងត្របែក រាជធានីភ្នំពេញ, E-mail : 4c@online.com.kh